

# ស្ថានភាពពន្ធនាគារនៅកម្ពុជា ឆ្នាំ២០០៧: រឿងនិទាន ម្ដាយ និង កូនស្រីម្នាក់

របាយការណ៍លីកាដូ
ខែមីនា ឆ្នាំ២០០៨

លីកាដូ
សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
Cambodian League for the Promotion and Defense of Human Rights
LICADHO

# ស្ថានភាពពន្ធនាគារនៅកម្ពុជា ២០០៧

# រឿងនិទាន ម្តាយ និង កូនស្រីម្នាក់

---

របាយការណ៍លីកាដូ

ខែមីនា ឆ្នាំ២០០៨

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

## សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងឃ្លាំមើលរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង ១២ ខេត្ត-ក្រុងផ្សេងទៀត។

**លីកាដូ កំពុងបន្តសកម្មភាពរបស់ខ្លួនតាមរយៈការិយាល័យកម្មវិធីទាំងប្រាំមួយរបស់ខ្លួនដូចខាងក្រោម:**

- **ការិយាល័យឯកសារ និងធនធានព័ត៌មាន** គឺជាការិយាល័យដែលរក្សាចងក្រងសំណុំរឿងទៅក្នុងទិន្នន័យដើម្បីងាយស្រួលក្នុងការរកឯកសារ និងវិភាគឱ្យបានឆាប់រហ័ស។
- **ការិយាល័យស៊ើបអង្កេត** គឺជាការិយាល័យដែលមានតួនាទីជាអ្នកស៊ើបអង្កេតករណីរំលោភសិទ្ធិមនុស្ស និងជួយជនរងគ្រោះនានាក្នុងដំណើរការបណ្តឹងដែលពាក់ព័ន្ធខាងផ្នែកច្បាប់។ បុគ្គលិក ដែលមានការហ្វឹកហ្វឺនជំនាញត្រឹមត្រូវក៏បានឃ្លាំមើលពន្ធនាគារចំនួន ១៨ ដើម្បីវាយតម្លៃស្ថានភាពពន្ធនាគារ ព្រមទាំងជួយឱ្យពិរុទ្ធជនទាំងឡាយទទួលបាននូវតំណាងផ្នែកច្បាប់ទៀតផង។
- **ការិយាល័យពេទ្យ** គឺជាការិយាល័យដែលផ្តល់សេវាវេជ្ជសាស្ត្រដល់ពិរុទ្ធជន ទណ្ឌិត និងមន្ត្រីពន្ធនាគារនៅតាមពន្ធនាគារចំនួន ១៨ កន្លែង។ ក្រៅពីនេះ ក៏បានផ្តល់សេវាវេជ្ជសាស្ត្រនិងជួយបញ្ជូនជនរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្សទៅមន្ទីរពេទ្យផងដែរ។
- **កម្មវិធីប្រឆាំងនឹងទារុណកម្ម** ជាការិយាល័យផ្តល់សេវាកម្មស្តារលទ្ធភាពទូទៅដល់ជនរងគ្រោះដោយអំពើទារុណកម្ម និងធ្វើការតស៊ូមតិប្រឆាំងនឹងអំពើទារុណកម្ម។
- **ការិយាល័យសិទ្ធិកុមារ** ជាការិយាល័យដែលផ្តល់ការអប់រំសិទ្ធិកុមារដល់សាធារណជនទូទៅ ស្ថាបនាបណ្តាញការពារកុមារនៅតាមមូលដ្ឋាននានា និងស៊ើបអង្កេតការរំលោភសិទ្ធិកុមារ ។
- **ការិយាល័យសិទ្ធិស្ត្រី** ជាការិយាល័យអប់រំសិទ្ធិស្ត្រីដល់សាធារណជនទូទៅ ស៊ើបអង្កេតការរំលោភសិទ្ធិស្ត្រី និងធ្វើការតស៊ូមតិ ដើម្បីឱ្យមានការផ្លាស់ប្តូរផ្នែកច្បាប់ និងសង្គម។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទង:**

លោកស្រី វេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការលីកាដូ
អាសយដ្ឋាន: អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)
ផ្ទះលេខ ១៦, ផ្លូវលេខ ៩៩, រាជធានីភ្នំពេញ, កម្ពុជា
ទូរស័ព្ទ: (៨៥៥) ២៣ ៣៦០ ៩៦៥ / ៣៦៤៩០១
ទូរសារ: (៨៥៥) ២៣ ៣៦០ ៩៦៥ / ២១៧ ៦២៦
អ៊ីម៉ែល: contact@licadho.org
គេហទំព័រ: http://www.licadho.org/

# មាតិកា


**១.	បុព្វកថា ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~១**

**២.	ការរស់នៅក្នុងពន្ធនាគារៈ រឿងរបស់ម្ដាយម្នាក់~~~~~~~~~~~~~~~~~~~~~~៥**

ការចាប់ខ្លួន និង ការជាប់ពន្ធនាគារ--------------------------------------- ៥

ការនាំកូនរបស់ខ្ញុំមករស់នៅក្នុងពន្ធនាគារ ---------------------------------៦

ស្ថានភាពរស់នៅប្រចាំថ្ងៃក្នុងពន្ធនាគារ ----------------------------------៧

ម្ហូបអាហារ និង ទឹក ------------------------------------------------- ៩

សម្លៀកបំពាក់ ---------------------------------------------------------១០

ការរស់នៅក្នុងពន្ធនាគារជាមួយកូន ---------------------------------- ១១

អំពើហិង្សាពីសំណាក់មន្ត្រីពន្ធនាគារ -------------------------------- ១២

អំពើហិង្សាពីសំណាក់ទណ្ឌិតដូចគ្នា ------------------------------------១៤

ការប្រព្រឹត្តិរបស់មន្ត្រីពន្ធនាគារចំពោះកូនខ្ញុំ និង ភ្ញៀវនានា --------------------១៥

រស់នៅក្នុងពន្ធនាគារជាមួយ ម៉ាលី : ចំណុចល្អ និង អាក្រក់------------------- ១៦

សម្ដីចុងក្រោយរបស់ លីណា -------------------------------------- ១៧

**៣.	ជីវិតរស់នៅក្នុងពន្ធនាគារៈ រឿងរបស់កុមារីម្នាក់ ~~~~~~~~~~~~~~~~~~ ១៨**

រឿងរបស់ម៉ាលី ------------------------------------------------ ១៨

**៤.	គម្រោងផ្ដល់ជំនួយម្ហូបអាហារដល់កុមារ និង នារីមានផ្ទៃពោះក្នុងពន្ធនាគារ ២២**

**៥.	អនុសាសន៍ និង សេចក្ដីសន្និដ្ឋាន ~~~~~~~~~~~~~~~~~~~~~~~~~~~~ ២៤**

(ខ) របាយការណ៍ លីកាដូ

# សេចក្ដីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណជាអនេកប្បការចំពោះ លីណា (ម្ដាយ) និង ម៉ាលី (កូន) ក្នុងរបាយការណ៍នេះ ចំពោះការចែករំលែកនូវរឿងរ៉ាវរបស់ពួកគេដោយស្មោះត្រង់ រឹងប៉ឹង និង ស្មោះស្ម័គ្រ និង ផ្ដល់ការអនុញ្ញាតឱ្យចុះផ្សាយរឿងនេះ ដោយសេចក្ដីសង្ឃឹមថា ស្ត្រី និង កុមារដទៃទៀតដែលរស់នៅក្នុងពន្ធនាគារ នឹងទទួលបានឱកាសរស់នៅប្រសើរជាងនេះក្នុងឆាកជីវិត ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះអង្គការដៃគូនានាទាំងមុន និង បច្ចុប្បន្នក្នុងការជួយជ្រោមជ្រែងគម្រោងផ្ដល់ជំនួយម្ហូបអាហារដល់កុមារ និង ស្ត្រីមានផ្ទៃពោះក្នុងពន្ធនាគារ និងអរគុណចំពោះសប្បុរសជនទាំងឡាយដែលបានផ្ដល់អំណោយឧបត្ថម្ភដល់កុមារ ម្ដាយកុមារ និង ស្ត្រីមានផ្ទៃពោះរស់នៅក្នុងពន្ធនាគារកម្ពុជា ។

ការបោះពុម្ពរបាយការណ៍នេះត្រូវបានឧបត្ថម្ភថវិកាដោយសហគមន៍អឺរ៉ុប ។ លីកាដូ ជាអ្នកទទួលខុសត្រូវទាំងស្រុងចំពោះខ្លឹមសារនៃរបាយការណ៍នេះ ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈនៃសហគមន៍អឺរ៉ុបឡើយ ។

# ១. បុព្វកថា

មកដល់ត្រឹមខែកុម្ភៈ ឆ្នាំ២០០៨ កន្លងទៅនេះ មាននារីចំនួន ៥៦២ នាក់ កំពុងរស់នៅក្នុងពន្ធនាគារ ១៨ ក្នុងចំណោមពន្ធនាគារ ២៦ នៅកម្ពុជា។[១] ក្នុងចំណោមនារីទាំងនោះ នារី៤នាក់មានផ្ទៃពោះ ហើយនារី៤៣នាក់ បានយកកូនមករស់នៅជាមួយក្នុងពន្ធនាគារ ឬ បានសម្រាលកូនក្នុងអំឡុងជាប់នៅក្នុងពន្ធនាគារ សរុបមានកុមារចំនួន ៥០ នាក់កំពុងរស់នៅក្នុងពន្ធនាគារជាមួយម្តាយ ។

នារីទាំងនោះត្រូវជាប់ពន្ធនាគារដោយសារមូលហេតុផ្សេងៗ ប៉ុន្តែក្នុងចំណោមមូលហេតុទាំងនោះ មានមូលហេតុមួយចំនួនដែលជួបប្រទះជាញឹកញាប់បំផុត ដែលនារីត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅពន្ធនាគារតែម្តងនៅកម្ពុជាដូចជា ការជួញដូរគ្រឿងញៀន (នារីភាគច្រើនដើរតួជាអ្នកដឹកជញ្ជូនគ្រឿងញៀននៅក្នុងកម្ពុជា និងពីកម្ពុជាទៅកាន់ប្រទេសជាប់ព្រំដែន) អំពើជួញដូរមនុស្ស និង ឃាដកម្ម (ភាគច្រើនកើតឡើងពេលនារីការពារខ្លួនក្នុងអំពើហិង្សាក្នុងគ្រួសារ)[២] ។ នារីជាច្រើនក៏បានបម្រើទោសយូរថែមទៀត នៅក្នុងដំណាក់កាលជាប់ទោសបណ្តោះអាសន្ន រង់ចាំការកាត់ទោស ហើយច្រើនតែត្រូវផ្តន្ទាទោសរយៈពេលវែង ដោយសារតែពួកគេជានារីក្រីក្រ ឬ ពុំមានលទ្ធភាពសូកសំណូក ដើម្បីបានដោះលែងឱ្យឆាប់ជាងនេះ ឬ ជាប់ពន្ធនាគារក្នុងរយៈពេលខ្លីជាងនេះ ឬ ដើម្បីឱ្យមានការកាត់ទោសត្រឹមត្រូវជាងនេះទៀត។ នារីភាគច្រើនពុំមានលទ្ធភាពទទួលបានតំណាងផ្នែកច្បាប់គ្រប់គ្រាន់ទេ ហើយគេច្រើនតែមិនបានប្រាប់នារីអំពីបញ្ហានេះផង ព្រមទាំងគ្មានការជួយជ្រោមជ្រែងនៅពេលស្ថិតនៅក្នុងការឃុំខ្លួនថែមទៀត។ នារីជាច្រើនទៀត ក៏ពុំបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការប្តឹងឧទ្ធរណ៍ផងដែរ ។ កត្តាទាំងឡាយខាងលើនេះ បង្ហាញឱ្យឃើញផ្នែកមួយអំពីមូលហេតុដែលនាំឱ្យចំនួនទណ្ឌិតនារីនៅពន្ធនាគារមានការកើនឡើងពីចំនួន ៣៥៦ នាក់ កាលពីខែកុម្ភៈ ឆ្នាំ២០០៥ រហូតដល់ ៥៦២ នាក់ ក្នុងខែកុម្ភៈ ឆ្នាំ២០០៨ ។

ជីវិតនៅក្នុងពន្ធនាគារកម្ពុជា គឺគ្រោតគ្រាតហួសហេតុជាទីបំផុតសម្រាប់មនុស្សគ្រប់គ្នា។ កង្វះម្ហូបអាហារ និង ទឹកស្អាត ភាពចង្អៀតណែននៅក្នុងបន្ទប់ឃុំឃាំង និង ការពុំអនុញ្ញាតឱ្យទណ្ឌិតទទួលបាននូវសេវាសុខភាព និង

---

[១] អង្គការលីកាដូឃ្លាំមើលពន្ធនាគារត្រឹមតែ ១៨ប៉ុណ្ណោះ ក្នុងចំណោមពន្ធនាគារទាំង២៦នៅកម្ពុជា (សូមមើលលេខយោងទី៦)។ គិតត្រឹមចុងឆ្នាំ២០០៧ មានអ្នកទោសនារីចំនួន ៦៤៨ នាក់ នៅក្នុងពន្ធនាគារទាំង២៦នៅកម្ពុជា (របាយការណ៍ប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានពន្ធនាគារប្រចាំឆ្នាំ២០០៧ និងទិសដៅឆ្នាំ២០០៨ -ក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានពន្ធនាគារខែកុម្ភៈ ឆ្នាំ២០០៨)

[២] កិច្ចការពារខ្លួនមិនត្រូវបានចាត់ទុកថាជាអំពើស្របច្បាប់ទេ នៅក្នុងច្បាប់នានានៅកម្ពុជា ហើយក្នុងការអនុវត្តជាក់ស្តែង ចៅក្រម អាចលើក ឬ អាចមិនលើកយកករណីបែបនេះមកពិចារណាឱ្យបានត្រឹមត្រូវនៅក្នុងការវិនិច្ឆ័យ។ អាចមាននារីជាច្រើន ដែលត្រូវបានឃុំខ្លួនដោយសារករណីឃាដកម្មនៅកម្ពុជា ពីព្រោះពួកគេបានសម្លាប់ប្តី ឬ ដៃគូដែលប្រព្រឹត្តអំពើហិង្សាមកលើខ្លួន។ នារីទាំងនោះអាចត្រូវបានផ្តន្ទាទោសរយៈពេលយ៉ាងយូរពី (១៥-២០ឆ្នាំ ឬ លើសពីនេះ) ទោះបីជាពួកគេគ្រាន់ការពារខ្លួននៅក្នុងការប្រឈមដោយផ្ទាល់ជាមួយការវាយដំពីសំណាក់ប្តីរបស់ពួកគេក៏ដោយ ។

អំពើហិង្សាមកលើទណ្ឌិតនានាពីសំណាក់មន្ត្រីពន្ធនាគារ និង ទណ្ឌិតដូចគ្នានោះ ក៏ជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃ ។ ជីវិតនៅក្នុងពន្ធនាគារកាន់តែលំបាកជាងនេះថែមទៀត នៅពេលដែលនារីមានផ្ទៃពោះ ឬ នារីយកកូនមករស់នៅជាមួយខ្លួនក្នុងពន្ធនាគារ ។

បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាផ្តល់ថវិកាត្រឹមតែ ១៥០០ រៀលប៉ុណ្ណោះ (០.៣៨ ដុល្លារ) សម្រាប់អ្នកទោសម្នាក់ក្នុងមួយថ្ងៃ ។ ថវិកានេះ គឺសម្រាប់ចំណាយម្ហូបអាហារ ទឹក អគ្គិសនី សម្លៀកបំពាក់ ថ្នាំពេទ្យ និង ការចំណាយផ្សេងៗទៀត។ ពេលដែលនារីណាម្នាក់មានផ្ទៃពោះ ឬ យកកូនតូចមករស់នៅជាមួយក្នុងពន្ធនាគារ ថវិកានេះត្រូវបែងចែកជាពីររវាងម្តាយ និង កូន។ ពុំមានការផ្តល់ថវិកាបន្ថែមដល់នារីមានផ្ទៃពោះ ឬ នារីយកកូនមករស់នៅជាមួយក្នុងពន្ធនាគារ ដើម្បីទិញម្ហូបអាហារ ទឹក ឬ ចំណាយការព្យាបាលឡើយ។ គ្មានទីកន្លែងរស់នៅផ្សេងសម្រាប់គ្រួសារទាំងនេះទេ ហើយកុមារច្រើនតែជាប់សោនៅក្នុងបន្ទប់ឃុំឃាំងដ៏ចង្អៀតណែន ហើយត្រូវតែញ៉ាំម្ហូបអាហារដែលជាចំណែករបស់ម្តាយខ្លួន។ ឃើញមានការផ្តល់ការអប់រំរៀនសូត្រតិចតួច ឬ ស្ទើរតែគ្មានសោះដល់កុមារទាំងឡាយដែលគ្រប់អាយុត្រូវចូលរៀន។ នារីមានផ្ទៃពោះទាំងឡាយមិនត្រូវបានអនុញ្ញាតឱ្យមានការថែទាំសុខភាពចាំបាច់មុន និងក្រោយសម្រាលកូនទេ ហើយក្នុងករណីខ្លះទៀតពួកគេត្រូវបានបង្ខំឱ្យសម្រាលកូននៅក្នុងពន្ធនាគារក៏មាន។ កុមារទាំងឡាយបានឃើញផ្ទាល់ភ្នែកនូវអំពើហិង្សាដែលកើតឡើងនៅក្នុងបរិវេណពន្ធនាគារជាប្រចាំ ហើយពុំឃើញមានវិធានការការពារពិសេសណាមួយត្រូវបានបង្កើតឡើង ដើម្បីធានាសុវត្ថិភាពដល់កុមារទាំងនេះទេ។ ជាក់ស្តែង កុមារទាំងនេះជាមនុស្សបម្រើទោសក្នុងពន្ធនាគារជាមួយម្តាយរបស់ពួកគេ ។

ក្នុងខែមិថុនា ឆ្នាំ២០០២ លីកាដូបានចេញផ្សាយរបាយការណ៍មួយមានចំណងជើងថា "មនុស្សគ្មានទោសក្នុងពន្ធនាគារៈ ជារបាយការណ៍លីកាដូស្តីពីសិទ្ធិកុមារ ដែលធំដឹងក្តីនៅក្នុងពន្ធនាគារ"។ របាយការណ៍នេះបានរកឃើញថា កុមារទាំងឡាយរស់នៅក្នុងពន្ធនាគារ ម្តាយរបស់កុមារ និង នារីមានផ្ទៃពោះ "ត្រូវបានរារាំងមិនឱ្យទទួលបាននូវសេវាកម្មសុខភាពសមរម្យ ម្ហូបអាហារគ្រប់គ្រាន់ ការសិក្សាអប់រំ និង សិទ្ធិមនុស្សជាមូលដ្ឋានទេ"។ បន្ទាប់ពីចេញរបាយការណ៍នោះមក គម្រោងមួយដែលមានចំណងជើងថា គម្រោងផ្តល់ជំនួយម្ហូបអាហារដល់កុមារ និងនារីមានផ្ទៃពោះក្នុងពន្ធនាគារ ត្រូវបានផ្តួចផ្តើមឡើងដោយលីកាដូ កាលពីឆ្នាំ២០០៣ កន្លងទៅ ដើម្បីប្រមែប្រមូល និងសម្របសម្រួលជំនួយរបស់សប្បុរសជន និង អង្គការនានាផ្តល់ឱ្យទារក កុមារតូចៗ និង នារីមានផ្ទៃពោះក្នុងពន្ធនាគារ ។ តាមច្បាប់ កុមារត្រូវបានអនុញ្ញាតឱ្យរស់នៅជាមួយម្តាយក្នុងពន្ធនាគាររហូតដល់អាយុ ៦ឆ្នាំ ប្រសិនបើពុំមានកន្លែងណាផ្សេងខាងក្រៅពន្ធនាគារអាចជួយថែទាំបានទេ។ គម្រោងផ្តល់ជំនួយម្ហូបអាហារដល់កុមារ និង នារីមានផ្ទៃពោះក្នុងពន្ធនាគារ គាំទ្រការសម្រេចចិត្តរបស់ម្តាយក្នុងការចិញ្ចឹមកូនក្នុងពន្ធនាគារ និង ផ្តល់ជំនួយដល់ការចិញ្ចឹមនេះ ។ ប៉ុន្តែ ក្នុងអាណត្តិដំបូងនៃគម្រោងនេះ (ជំហ៊ានទី១) លីកាដូ បានរកឃើញថា ពួកគេទាំងនោះត្រូវការជំនួយតាមបែបទម្រង់ផ្សេងៗជាច្រើនទៀត ដូចជាការថែទាំសុខភាពជាប្រចាំ ការអប់រំសម្រាប់កុមារ និង ម្តាយ

ទាំងឡាយ ព្រមទាំងការបង្កឱ្យមានទំនាក់ទំនងភ្ជាប់ជាមួយសង្គមកម្ពុជាជាដើម ។ គម្រោងផ្ដល់ជំនួយម្ហូបអាហារដល់កុមារ និង នារីមានផ្ទៃពោះក្នុងពន្ធនាគារ មានគោលបំណងពង្រីកជំហ៊ានទី២ ដែលសំដៅដោះស្រាយតម្រូវការផ្សេងៗថែមទៀត ។គម្រោងនេះនឹងត្រូវបានពិភាក្សាលំអិតជាងនេះទៀតនៅផ្នែកខាងក្រោមនៃរបាយការណ៍នេះ ។



របាយការណ៏នេះលើកយករឿងរ៉ាវពិសេសរបស់នារីជាម្ដាយ និង កូនម្នាក់[៣] ដែលបានចំណាយពេលជាច្រើនឆ្នាំរស់នៅក្នុងពន្ធនាគារជាមួយគ្នា ក្នុងប្រព័ន្ធពន្ធនាគារកម្ពុជា។ រឿងរបស់ម្ដាយ និង កូននេះ គឺដូចរឿងរបស់នារី និង កុមារផ្សេងៗទៀតដែលរស់នៅក្នុងពន្ធនាគារដែរ ។ ស្ថានភាពមួយដែលកុមារតូចៗចូលមករស់នៅក្នុងពន្ធនាគារជាមួយម្ដាយរបស់ខ្លួន ក្នុងកំឡុងពេលជាប់ឃុំបណ្ដោះអាសន្នរង់ចាំការវិនិច្ឆ័យទោស ហើយរយៈពេលក្រោយមកកុមារនោះធំដល់អាយុដែលមិនអាចអនុញ្ញាតឱ្យរស់នៅក្នុងប្រព័ន្ធពន្ធនាគារ[៤] តទៅទៀតបាន ហើយត្រូវបង្ខំឱ្យចាកចេញពីម្ដាយនៅក្នុងពន្ធនាគារដែលត្រូវបម្រើទោសយ៉ាងយូរហួសប្រមាណ ។ ប៉ុន្តែ ចំណុចសំខាន់ត្រូវបានយល់ថា រឿងនេះគ្រាន់តែឆ្លុះបញ្ចាំងនូវបទពិសោធន៏ទាំងឡាយរបស់នារី និង កូនម្នាក់តែប៉ុណ្ណោះ ហើយក៏ពុំមែនតំណាងឱ្យបទពិសោធន៏របស់នារី និង កុមារទាំងឡាយរស់នៅក្នុងពន្ធនាគារទេ ។ ស្ថានភាពរស់នៅរបស់ទណ្ឌិតនារី និង កូនៗរបស់ពួកគេ មានភាពខុសៗគ្នា អាស្រ័យទៅតាមពន្ធនាគារនីមួយៗ ហើយពន្ធនាគារខ្លះមានស្ថានភាព ឬ អាគារល្អ ឬ អាក្រក់ជាងពន្ធនាគារផ្សេងៗទៀត ។

របាយការណ៏នេះមិនធ្វើការពិភាក្សាអំពីទណ្ឌិត ឬ ពិរុទ្ធជនដែលជាអនីតិជនទេ នោះគឺផ្ដោតលើកុមារដែលមានអាយុក្រោម ១៨ ឆ្នាំ ហើយក៏មិនបានពិភាក្សាអំពីស្ថានភាពរស់នៅរបស់ទណ្ឌិតទូទៅក្នុងពន្ធនាគារដែរ ។ ចំពោះព័តិមានបន្ថែមទាក់ទងជាមួយស្ថានភាពរស់នៅក្នុងពន្ធនាគាររបស់ទណ្ឌិតទូទៅ សូមអានរបាយការណ៏ លីកាដូដែលមានចំណងជើងថា "ស្ថានភាពពន្ធនាគារនៅកម្ពុជា ២០០៥ និង ២០០៦: ថ្ងៃមួយក្នុងជីវភាពរស់នៅជា..." ។[៥]

[៣] ឈ្មោះ និង អត្តសញ្ញាណទាំងអស់ត្រូវបានដូរ ដើម្បីការពារកិត្តិយសរបស់អតិថិជន ។

[៤] មានតែកុមារអាយុក្រោម ៦ ឆ្នាំប៉ុណ្ណោះ ត្រូវបានអនុញ្ញាតឱ្យរស់នៅជាមួយម្ដាយនៅក្នុងពន្ធនាគារ ។ សូមមើលលេខយោងទី៨ ។

[៥] គេហទំព័រ : "HYPERLINK “http://www.licadho.org/reports.php?perm=104”"

(២) របាយការណ៍ លីកាដូ

ព័ត៌មាននៅក្នុងរបាយការណ៍នេះ ត្រូវបានចងក្រងដោយគម្រោងពន្ធនាគាររបស់លីកាដូ ។ អ្នកស្រាវជ្រាវពន្ធនាគារ លីកាដូ ចូលសម្ភាសន៍ ៤ ដង ក្នុងមួយខែ នៅក្នុងពន្ធនាគារ ១៨ ក្នុងចំណោមពន្ធនាគារសរុប ២៦ ទូទាំងកម្ពុជា [៦] ។ ការសម្ភាសន៍ដែលធ្វើឡើងដោយលីកាដូ គឺដើម្បីប្រមូលព័ត៌មានពិតប្រាកដដែលទាក់ទងជាមួយនឹងរឿងរ៉ាវរបស់ម្តាយ និង កូន ដោយមិនមានការឃ្លាំមើលពីមន្ត្រីពន្ធនាគារទេ ។

□□□

[៦] អ្នកស្រាវជ្រាវពន្ធនាគារលីកាដូ ចូលសម្ភាសន៍តែក្នុងពន្ធនាគារណាដែលនៅជិតការិយាល័យកណ្តាលក្នុងក្រុងភ្នំពេញ និងការិយាល័យខេត្តទាំង១២ ប៉ុណ្ណោះ ។ ពន្ធនាគារទាំងនោះមាន: ប៉េហ្ស៊ី (PJ) មណ្ឌលអប់រំកែប្រែទី១ (អតីត T3) មណ្ឌលអប់រំកែប្រែទី២ (សម្រាប់ឃុំឃាំងនារី និង អនីតិជន) មណ្ឌលអប់រំកែប្រែទី៣ (ត្រពាំងផ្លុង ឬ T5) ពន្ធនាគារយោធាទួលស្លែង តាខ្មៅ ក្រុងព្រះសីហនុ ខេត្តកំពង់ស្ពឺ កំពត កំពង់ឆ្នាំង កំពង់ចាម កំពង់ធំ ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប ស្វាយរៀង និង កោះកុង ។ អ្នកស្រាវជ្រាវលីកាដូឈប់ឃ្លាំមើល និង ចូលសម្ភាសន៍ពន្ធនាគារខេត្តព្រៃវែង និង តាកែវទៀតហើយ ។ ចំពោះខេត្តមណ្ឌលគីរី រតនគីរី ស្ទឹងត្រែង ក្រចេះ តាកែវ និង ព្រះវិហារ លីកាដូ ពុំមានការិយាល័យនៅក្នុងខេត្តទាំងនោះទេ ដូច្នេះពន្ធនាគារទាំងនោះ មិនត្រូវបានឃ្លាំមើល និង សម្ភាសន៍ដោយអ្នកស្រាវជ្រាវពន្ធនាគារលីកាដូទេ ។

# ២. ការរស់នៅក្នុងពន្ធនាគារៈ រឿងរបស់ម្តាយម្នាក់

## ការចាប់ខ្លួន និង ការជាប់ពន្ធនាគារ

*ខ្ញុំឈ្មោះ លីណា ជាទណ្ឌិតម្នាក់នៅក្នុងពន្ធនាគារនៃប្រទេសកម្ពុជា ។ ខ្ញុំបានជាប់នៅក្នុងពន្ធនាគារអស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ មុននឹងខ្ញុំត្រូវបានចាប់បញ្ជូនមកពន្ធនាគារនេះ ខ្ញុំមានមុខរបរ មានជីវភាពរស់នៅ និង កូនម្នាក់ដែលខ្ញុំស្រឡាញ់យ៉ាងខ្លាំង ។*

*មុននឹងខ្ញុំត្រូវបញ្ជូនមកពន្ធនាគារ ខ្ញុំបានបើកភោជនីយដ្ឋានមួយ ដែលមានមនុស្សប្រុស ៣ នាក់ និង ស្រី ៣ នាក់ ធ្វើការជាអ្នកបំរើ និងអ្នកជូតសំអាត ។ មួយសប្តាហ៏មុនពេលខ្ញុំត្រូវបានចាប់ខ្លួន មាននគរបាលបីនាក់បានចូលមកក្នុងភោជនីយដ្ឋានរបស់ខ្ញុំ ហើយបានប្រាប់ឱ្យខ្ញុំបង់ប្រាក់កាសឱ្យពួកគេខ្លះ ដើម្បីគេការពារសន្តិសុខ ។ ខ្ញុំប្រាប់ពួកគេថា ខ្ញុំគ្មានប្រាក់បង់ឱ្យទេ ពីព្រោះភោជនីយដ្ឋានរបស់ខ្ញុំទើបតែដំណើរការ ហើយជាភោជនីយដ្ឋានតូចតាចប៉ុណ្ណោះ ដូច្នេះខ្ញុំគ្មានលទ្ធភាពជូនទេ ។*

*មួយសប្តាហ៏ក្រោយមក ស្រាប់តែគេចាប់ខ្ញុំតែម្តង ដោយបទចោទប្រកាន់ពីបទជួញដូរមនុស្ស ។*

*នគរបាលចោទថា ខ្ញុំបានជួញដូរពួកអ្នកបំរើ និងអ្នកជូតសំអាតដែលធ្វើការនៅក្នុងភោជនីយដ្ឋានរបស់ខ្ញុំ ។ ខ្ញុំប្រាប់ពួកគេថា ខ្ញុំពុំបានប្រព្រឹត្តអំពើជួញដូរមនុស្សទេ ខ្ញុំគ្រាន់តែជាអ្នករកស៊ីបើកភោជនីយដ្ឋានតូចតាចតែប៉ុណ្ណោះ ប៉ុន្តែ នគរបាលនិយាយថា មានអតិថិជនម្នាក់បានរាយការណ៏ប្រាប់គេថា ខ្ញុំបានលក់ក្មេងស្រីតាមរយៈភោជនីយដ្ឋានរបស់ខ្ញុំ ។*

*ខ្ញុំមិនបានចាំច្បាស់អំពីសវនាការរឿងក្តីខ្ញុំទេ ដោយអ្វីៗទាំងអស់ហាក់ដូចជាកើតភ្លាមៗពេក ។ នៅក្នុងពេលសវនាការនោះ ខ្ញុំពុំបានចាំថា នរណាជាមេធាវីរបស់ខ្ញុំដែរ ហើយរហូតដល់ពេលនេះ ក៏ខ្ញុំនៅតែមិនស្គាល់ឈ្មោះគាត់ដែរ ។*

*តុលាការបានផ្តន្ទាទោសខ្ញុំដាក់ពន្ធនាគារជាច្រើនឆ្នាំ ។ ដំបូងខ្ញុំឮថា ខ្ញុំត្រូវជាប់ពន្ធនាគារត្រឹមតែ ៦ ឆ្នាំប៉ុណ្ណោះ ប៉ុន្តែនៅក្នុងពេលសវនាការ ចៅក្រមម្នាក់បានប្រាប់ខ្ញុំថា ប្រសិនបើខ្ញុំឱ្យប្រាក់កាសគាត់ខ្លះ ខ្ញុំអាចរក្សាការទទួលទោសត្រឹមនេះបាន ប៉ុន្តែបើខ្ញុំពុំមានប្រាក់កាសឱ្យគាត់ទេ នោះគាត់អាចនឹងបន្ថែមរយៈពេលផ្តន្ទាទោសថែមទៀត ។*

*ខ្ញុំគ្មានប្រាក់ជូនចៅក្រមទេ នៅពេលដែលគាត់សុំចំនួន ២០០០ដុល្លារ ដូច្នេះគាត់បន្ថែមរយៈពេលឃុំខ្លួនខ្ញុំដល់ទៅជាង ១០ ឆ្នាំ ។ ហេតុនេះ ខ្ញុំត្រូវជាប់ទោសជាច្រើនឆ្នាំតទៅមុខទៀត ។*

បទពិសោធន៍របស់លីណា គឺជាបទពិសោធន៍មួយដែលនារីកម្ពុជាជាច្រើនជាប់ពន្ធនាគារ បានជួបប្រទះដូចគ្នាដែរ ។

លីកាដូ បានទទួលរបាយការណ៍របស់នារីទាំងឡាយដែលជាប់ពន្ធនាគារដោយបទឧក្រិដ្ឋដែលពួកគេមិនបានប្រព្រឹត្ត និង/ឬ ត្រូវបានផ្តន្ទាទោសដោយមិនសមហេតុផល ដោយសារតែពួកគេមិនមានលទ្ធភាពបង់ប្រាក់កាសក្រៅផ្លូវការ ដែលជាទូទៅមានចំនួនច្រើនហួសពេក ។

ស្រដៀងគ្នានេះដែរ លីកាដូបានទទួលរបាយការណ៍ថា ទណ្ឌិត (ទាំងបុរស នារី និង អនីតិជន) មិនត្រូវបានអនុញ្ញាតឱ្យមានមេធាវីដែលមានសមត្ថភាពគ្រប់គ្រាន់ មកពន្យល់អំពីដំណើរការច្បាប់ និង សិទ្ធិរបស់ខ្លួនអំពីដំណើរការសវនការយុត្តិធម៌ និង បណ្តឹងឧទ្ធរណ៍ទេ ។

## ការនាំកូនរបស់ខ្ញុំមករស់នៅក្នុងពន្ធនាគារ

*ពេលខ្ញុំចូលមកដល់ពន្ធនាគារ ខ្ញុំគ្មានជម្រើសទេ ដូច្នេះខ្ញុំត្រូវតែយកកូនមកជាមួយខ្ញុំ ។ កូនខ្ញុំឈ្មោះ ម៉ាលីពេលនោះនាងនៅតូចណាស់ ។ ប្តីខ្ញុំស្លាប់ចោលខ្ញុំ ហើយខ្ញុំគ្មានសាច់ញាតិនៅជិតដែលអាចជួយមើលកូនខ្ញុំបានទេ ។ ម៉ាលីនៅតូចណាស់ ដូច្នេះ នាងមិនបានយល់អ្វីទាំងអស់ដែលបានកើតឡើង ហើយក៏មិនយល់ថា រស់នៅក្នុងពន្ធនាគារនេះ មានន័យយ៉ាងណាដែរ ប៉ុន្តែខ្ញុំមានការសោកស្តាយយ៉ាងខ្លាំងនៅក្នុងចិត្ត ដែលកូនខ្ញុំត្រូវរស់នៅក្នុងបន្ទប់ឃុំឃាំងដូចទណ្ឌិត និងបានក្លាយទៅជាទណ្ឌិតម្នាក់ដែរ ។*

នៅក្នុងពន្ធនាគារកម្ពុជាភាគច្រើន ទណ្ឌិតបុរស និង នារីត្រូវបានបង្ខំឱ្យរស់នៅក្នុងពន្ធនាគារជាមួយគ្នា ។ ដោយគ្រាន់តែមានបន្ទប់ឃុំឃាំងញែកចេញពីបុរស និង នារី ហើយតាមពិតទៅគឺមានតែពន្ធនាគារមួយតែប៉ុណ្ណោះសម្រាប់ឃុំឃាំងអ្នកទោសនារីនៅកម្ពុជា គឺមណ្ឌលអប់រំកែប្រែទី២ ។[៧]

ចាប់តាំងពីឆ្នាំ២០០២ ពេលដែលលីកាដូចាប់ផ្តើមស្រាវជ្រាវស្ថានភាពកុមាររស់នៅក្នុងពន្ធនាគារជាមួយម្តាយ លទ្ធផលបង្ហាញថា មានកុមារជាង ១១០ នាក់ ដែលបានចូលមករស់នៅក្នុងប្រព័ន្ធពន្ធនាគារជាមួយម្តាយរបស់ពួកគេ ។

[៧] មណ្ឌលអប់រំកែប្រែទី ២ (ម២) នៅក្រៅរាជធានីភ្នំពេញ — ពន្ធនាគារនេះក៏ប្រើសម្រាប់ឃុំឃាំងទណ្ឌិតជាអនីតិជនផងដែរ ។

កុមារភាគច្រើនរស់នៅក្នុងមណ្ឌលលអប់រំកែប្រែទី២ ប៉ុន្តែ មានកុមារមួយចំនួនរស់នៅតាមពន្ធនាគារខេត្ត ដែលត្រូវបានបង្ខំឱ្យរស់នៅក្នុងបន្ទប់ឃុំឃាំងពន្ធនាគារជាប់នឹងបន្ទប់ឃុំឃាំងទណ្ឌិតបុរស ដែលពួកគេខ្លះត្រូវបានកាត់ទោសពីបទប្រព្រឹត្តបទល្មើសផ្លូវភេទ និង/ឬ បទល្មើសហិង្សាមកលើកុមារ។ បញ្ហានេះ ជាការផ្ទុយទៅនឹងបទបញ្ញត្តិអប្បបរមារបស់អង្គការសហប្រជាជាតិសម្រាប់ប្រព្រឹត្តចំពោះទណ្ឌិត បទបញ្ញត្តិ ៨(ក) ដែលចែងថា "ទណ្ឌិតបុរស និង នារី ត្រូវដាក់ឃុំដាច់ដោយឡែក និងឱ្យបានឆ្ងាយពីគ្នាតាមលទ្ធភាពដែលអាចធ្វើទៅបាន។ ចំពោះមន្ទីរឃុំឃាំងដែលទទួលយកទាំងទណ្ឌិតបុរស និង នារី នោះបរិវេណសំរាប់ដាក់អ្នកទោសនារីត្រូវតែនៅដាច់ដោយឡែកពីគ្នាជាដាច់ខាត"។

ករណីច្រើនទៀត ទណ្ឌិតបុរសក៏មានយកកូនមករស់នៅជាមួយក្នុងពន្ធនាគារដែរ។ ក្នុងករណីនេះ កូននោះត្រូវរស់នៅក្នុងបន្ទប់ឃុំឃាំងជាមួយឪពុក និង ទណ្ឌិតបុរសផ្សេងទៀត។ បច្ចុប្បន្ននេះ ពុំមានទណ្ឌិតបុរសយកកូនមករស់នៅជាមួយក្នុងពន្ធនាគារទេ ហើយបញ្ហានេះក៏មិនសូវមានច្រើនដែរ។

នៅក្នុងពន្ធនាគារកម្ពុជាជាច្រើន ពុំមានការបែងចែកឱ្យដាច់តាមភេទប្រុស ស្រី នៅក្នុងទីធ្លាពន្ធនាគារទេ ហេតុដូច្នេះ នារី និង កុមារទាំងឡាយអាចត្រូវស្ថិតលាយឡំគ្នាជាមួយទណ្ឌិតបុរស ដែលធ្លាប់បានប្រព្រឹត្តបទល្មើសហិង្សាផ្សេងៗជាច្រើន។

## ស្ថានភាពរស់នៅប្រចាំថ្ងៃក្នុងពន្ធនាគារ

*ពេលខ្ញុំចូលដល់ក្នុងពន្ធនាគារដំបូងជាមួយម៉ាលី ខ្ញុំមានការតក់ស្លុតយ៉ាងខ្លាំង ចំពោះស្ថានភាពរស់នៅដ៏លំបាកក្នុងបន្ទប់ឃុំឃាំងនៃពន្ធនាគារ ។ នៅក្នុងបន្ទប់នោះមាននារីចំនួន ២៥ នាក់ ហើយមានកុមារ ២ នាក់ផង ប៉ុន្តែ ចំនួននេះតែងតែផ្លាស់ប្តូររៀងរាល់សប្តាហ៍ ។*

*ទណ្ឌិតម្នាក់ៗត្រូវស្ថិតនៅក្នុងទំហំផ្ទៃប្រមាណ ៣ ហត្ថបួនជ្រុងប៉ុណ្ណោះ ហើយពិបាកគេងណាស់។ ខ្ញុំត្រូវគេងអង្គុញជើង កើយដៃ ដែលធ្វើឱ្យខ្ញុំឈឺចុកដៃជើងយ៉ាងខ្លាំង។*

*ខ្ញុំគេងមិនបានស្រួលទេនៅទីកន្លែងដ៏តូចចង្អៀត ហើយមានមនុស្សច្រើនពេក ព្រមទាំងមានក្លិនស្អុយ ក្តៅ ហើយម្យ៉ាងវិញទៀតដោយសារខ្ញុំគិតច្រើនផង ។ ជាធម្មតា ខ្ញុំភ្ញាក់ពីដំណេកនៅម៉ោង ៤.០០ ព្រឹក ជួនកាលម៉ោង ៥.០០ ឬ ម៉ោង ៦.០០ ព្រឹកក៏មាន ។ កងសន្តិសុខតែងតែបើកទ្វារបន្ទប់ឃុំឃាំងនៅម៉ោង ៨.០០ ព្រឹក ហើយពេលនោះគេនឹងអាចបើកឱ្យយើងចេញក្រៅរយៈពេល ២ ម៉ោង។ ខ្ញុំដឹងថា គេត្រូវអនុញ្ញាតឱ្យយើងនៅក្រៅបន្ទប់ឃុំឃាំងពីម៉ោង ៨.០០ រហូតដល់ម៉ោង ១០.០០ ព្រឹក ហើយពេលរសៀលពីម៉ោង ៣.០០ ទៅ ៤.០០ ។ ប៉ុន្តែតាមពិត*

(៨) របាយការណ៍ លីកាដូ

*ប្រសិនបើគ្មានប្រាក់គ្រប់គ្រាន់ឱ្យពួកអ្នកយាមទេ គេមិនឱ្យយើងចេញក្រៅទេ។ ដើម្បីបានចេញក្រៅ យើងត្រូវបង់ ២០០០ រៀល ក្នុងមួយថ្ងៃ ។ ខ្ញុំក្រណាស់ គ្មានលទ្ធភាពបង់ឱ្យអ្នកយាម ដើម្បីបានចេញមកខាងក្រៅទេ ដូច្នេះខ្ញុំត្រូវគេចាក់សោក្នុងបន្ទប់ជានិច្ច ព្រមទាំងមិនបានចេញមកខាងក្រៅតាមពេលម៉ោងកំណត់ផង។ ខ្ញុំត្រូវនៅក្នុងបន្ទប់ឃុំឃាំងយ៉ាងយូរ ច្រើនថ្ងៃ ឬ អាចដល់សប្តាហ៍ក៏មាន ដែលខ្ញុំមិនបានចេញពីបន្ទប់ឃុំឃាំងទាល់តែសោះ។*

*នៅក្នុងបន្ទប់គ្មានអ្វីច្រើនធ្វើទេ ។ អ្នកខ្លះគេង ឬ ជជែកគ្នា ។ ខ្ញុំប្រឹងព្យាយាមរៀនភាសាអង់គ្លេសតាមសៀវភៅដែលខ្ញុំមាន ។ រៀងរាល់ថ្ងៃ ខ្ញុំមានអារម្មណ៍មិនខុសប្លែកគ្នាទេ ហើយគិតថា ដូចជាពេលដ៏យូរណាស់។ រៀងរាល់យប់ ខ្ញុំព្យាយាមចូលគេងពីម៉ោង ៩.០០ យប់ ប៉ុន្តែដូចខ្ញុំបាននិយាយហើយថា វាពិបាកគេងណាស់។*

ភាពចង្អៀតនៃបន្ទប់ឃុំឃាំងក្នុងពន្ធនាគារ គឺជាបញ្ហាធម្មតាមួយនៃពន្ធនាគារកម្ពុជា។ ជាទូទៅពុំមានកន្លែងទូលាយ ឬ ខ្យល់អាកាសចេញចូលគ្រប់គ្រាន់សម្រាប់ទណ្ឌិតទេ។ ទណ្ឌិតនារីដែលមានកូននៅជាមួយនិយាយថា ពុំមានការបែងចែកកន្លែងសម្រាប់កុមារនៅក្នុងបន្ទប់ឃុំឃាំងទេ ហើយកុមារត្រូវបង្ខំឱ្យរស់នៅកន្លែងដ៏តូចចង្អៀតជាមួយម្តាយ។



លីកាដូបានទទួលរបាយការណ៍ពីទណ្ឌិតថា ជួនកាលមន្ត្រីពន្ធនាគារបដិសេធមិនអនុញ្ញាតឱ្យអ្នកទោសចេញពីបន្ទប់ឃុំឃាំងទេ ក្នុងពេលដែលត្រូវចេញមកហាត់ប្រាណ ប្រសិនបើទណ្ឌិតណាមិនបង់ប្រាក់ក្រៅផ្លូវការឱ្យពួកបុគ្គលិកទេ ។ ករណីរបស់លីណា នាងបានរាយការណ៍ថា នាងត្រូវបានចាក់សោទុកក្នុងបន្ទប់ឃុំឃាំងអស់រយៈពេលជាង ២ សប្តាហ៍ ពីព្រោះនាងពុំមានលទ្ធភាពបង់ថ្លៃប្រចាំថ្ងៃឱ្យបុគ្គលិកពន្ធនាគារ។ (ទណ្ឌិតខ្លះជួនកាលទទួលប្រាក់កាសពីក្រុមគ្រួសារ ឬ មិត្តភក្តិដែលចូលមកសួរសុខទុក្ខពួកគេ)។ នៅពេលដែលសួរទៅបុគ្គលិកពន្ធនាគារអំពីបញ្ហានេះ ពួកគេឆ្លើយថា ពួកគេសម្រេចមិនអនុញ្ញាតឱ្យទណ្ឌិតទាំងអស់ចាកចេញពីបន្ទប់ឃុំឃាំងក្នុងពេលតែមួយទេ ។ ពួកគេនិយាយបន្តថា នៅពេលដែលទណ្ឌិតមួយក្រុមបានបញ្ចប់ការហាត់ប្រាណហើយនោះ ទើបមួយក្រុមផ្សេងទៀតត្រូវបានអនុញ្ញាតឱ្យចេញជាបន្ត

បន្ទាប់ ដោយមួយក្រុមមានពេលត្រឹមតែ ២ ម៉ោងប៉ុណ្ណោះ ។ លីកាដូមិនអាចបញ្ជាក់ច្បាស់ថា តើការអនុវត្តិបែបនេះ ត្រូវបានធ្វើបន្តដែរ ឬ អត់ទេ ប៉ុន្តែរបាយការណ៍នានាបានមកពីទណ្ឌិតមួយចំនួនមានលក្ខណៈផ្ទុយគ្នាពីរបាយការណ៍ របស់មន្ត្រី ។ វាហាក់ដូចជាមិនទំនងទាល់តែសោះ ដែលមន្ត្រីពន្ធនាគារបង្កើតឱ្យមានការងារត្រួតពិនិត្យលើទណ្ឌិត ទ្វេដង តាមរយៈការអនុញ្ញាតឱ្យទណ្ឌិតចេញហាត់ប្រាណជាក្រុមៗខុសពេលគ្នា លើសពីរយៈពេលដែលបានកំណត់ ២ ម៉ោងនោះ ។

ទណ្ឌិតខ្លះបានរាយការណ៍ថា ពួកគេត្រូវបង្ខំឱ្យធ្វើការងារពលកម្មជាច្រើនដូចជា ថែសួន កាត់ដេរ បោក-គក់ និង ដាំស្លសម្រាប់ពួកមន្ត្រីពន្ធនាគារ និង កិច្ចការផ្សេងៗទៀតជាច្រើន ដែលជាផ្នែកមួយនៃការដាក់ទោស ។ អ្នកស្រាវជ្រាវពន្ធនាគារលីកាដូ បានសង្កេតឃើញថា ទណ្ឌិតត្រូវធ្វើការក្រោមកំដៅថ្ងៃច្រើនម៉ោង ដោយគ្មានទឹកពិសា ម្លប់ជ្រក ម្ហូបអាហារ ឬ ការសម្រាកសោះ ។ ពលកម្មដោយបង្ខំនេះ អាចប្រៀបប្រដូចបាននឹងការងារទាសករ ដោយទណ្ឌិតទាំងនោះពុំបានទទួលប្រាក់កម្រៃចំពោះការងារដែលពួកគេបញ្ចេញពលកម្មឡើយ ព្រមទាំងបង្ខំឱ្យធ្វើក្រោមស្ថានភាពដ៏លំបាកទៀតផង ។

## ម្ហូបអាហារ និង ទឹក

*គេឱ្យបាយយើងពិសាពីរពេលក្នុងមួយថ្ងៃ គឺអាហារពេលថ្ងៃត្រង់ និង ពេលល្ងាច ។ ជួនកាលគេឱ្យយើងពិសាបាយព្រឹកនៅម៉ោង ១០ ឬ ម៉ោង ១១ ក៏មានដែរ ហើយយើងពិសាបាយល្ងាចម៉ោង ៤.០០ រសៀល ។ ការអនុវត្តិបែបនេះ គេអត់ឱ្យយើងពិសាបាយថ្ងៃត្រង់ទេ ។ ចំពោះអាហារទាំងពីរពេលនោះ ជាធម្មតាបាយចំអិនពីអង្កមិនមានគុណភាព បាយពណ៌ស្រអាប់ គ្មានរសជាតិទេ ហើយពេលខ្លះមានសត្វល្អិតក្នុងបាយនោះទៀតផង ។ ពេលណា មានសំណាងក៏បានត្រីមួយដុំពិសាទៅ ។ រាល់ថ្ងៃខ្ញុំស្រេកឃ្លានខ្លាំងណាស់ ។*

*ចំពោះទឹកវិញ គេឱ្យយើងពិសាទឹកអត់ស្អាតទេ ទឹកនោះជួនកាលពណ៌ខ្មៅ ដែលបណ្ដាលឱ្យឈឺ ។ ពេលកូនខ្ញុំរស់នៅទីនេះ ពេលខ្លះឈឺធ្ងន់មែនទែន ដោយសារទឹកមិនស្អាតនេះ ។ ប្រសិនបើគ្មានប្រាក់កាស ដើម្បីទិញធ្យូងដាំទឹកទេ ឬ គ្មានប្រាក់កាសទិញទឹកបរិសុទ្ធពិសាទេ មានតែទ្រាំពិសាទឹកបែបនេះ ។*

ការត្អូញត្អែរអំពីបរិមាណ និង គុណភាពម្ហូបអាហារ ព្រមទាំងទឹកស្អាត គឺជាការត្អូញត្អែរមួយដែលមានកំរិតខ្ពស់ជាងគេក្នុងចំណោមការត្អូញត្អែរជាច្រើន ដែលត្រូវបានរាយការណ៍ពីបណ្ដាលអ្នកស្រាវជ្រាវពន្ធនាគារ ។

(១០) របាយការណ៍ លីកាដូ



ទណ្ឌិតជាច្រើនពុំមានទឹកពិសាជាប្រចាំទេ ហើយពន្ធនាគារខ្លះទៀតគ្មានទឹក ឬ គ្មានបង្គន់នៅក្នុងបន្ទប់ឃុំឃាំងផង។ ប្រសិនបើទណ្ឌិតណាគ្មានប្រាក់កាសទិញទឹកពិសា ឬ ទិញធុងសម្រាប់ដុតដាំទឹកទេ ទណ្ឌិតបែបនោះនឹងត្រូវបង្ខំចិត្តពិសាទឹកមិនស្អាត ឬ អត់មានទឹកពិសាតែម្តង។

ទណ្ឌិតជាច្រើនជួបប្រទះជម្ងឺកង្វះជីវជាតិ និង បញ្ហាសុខភាពធ្ងន់ធ្ងរ ដោយសារតែកង្វះម្ហូបអាហារ ហើយកុមាររស់នៅក្នុងពន្ធនាគារជាអ្នកប្រឈមនឹងគ្រោះថ្នាក់ខ្លាំងជាងគេបំផុត។ ទណ្ឌិតដែលមានផ្ទៃពោះ ឬ មានកូនរស់នៅជាមួយក្នុងពន្ធនាគារ ពុំបានទទួលម្ហូបអាហារ ឬ របបអាហាររូបត្ថម្ភបន្ថែមទេ ហេតុនេះធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះពីបញ្ហាសុខភាពថែមទៀត ។ ទណ្ឌិតខ្លះរាយការណ៍ថា ពួកគេមិនដែលបានពិសាសាច់ និង ទឹកដោះគោទេ ចំណែកត្រី និង ផ្លែឈើក៏កម្របានពិសាដែរ ហើយបន្លែពណ៌បៃតងវិញ ជួនកាលបានពិសាខ្លះ៧ដែរ នៅពេលទទួលទានអាហារ។ មន្ត្រីពន្ធនាគារបានផ្តល់អាហារឱ្យទណ្ឌិតម្នាក់មិនលើសពីពីរដងក្នុង ១ថ្ងៃទេ ។

## សម្លៀកបំពាក់

*តាំងពីខ្ញុំចូលមកដល់ទីនេះពីដំបូង ជាងបួនឆ្នាំកន្លងទៅហើយ គេឱ្យសម្លៀកបំពាក់ដែលជាឯកសណ្ឋានទណ្ឌិតដល់ខ្ញុំតែមួយកំប្លេប៉ុណ្ណោះ ។ ពីម្សិលមិញ ខ្ញុំស្លៀកសម្លៀកបំពាក់ពន្ធនាគារនោះ ហើយថ្ងៃនេះខ្ញុំបោកគក់វា ដូច្នេះខ្ញុំត្រូវពាក់អាវដៃវែងនេះសិនទៅ ។ ខ្ញុំដាំស្លច្រើនសម្រាប់ទណ្ឌិតដទៃទៀត ដោយគេឱ្យប្រាក់កាសខ្ញុំខ្លះ តែខ្ញុំសុំគេតែបាយសបន្តិចបន្តួចប៉ុណ្ណោះ ហើយនៅពេលណាដែលមានទណ្ឌិតណាត្រូវគេដោះលែង គេទុកសម្លៀកបំពាក់ខ្លះឱ្យខ្ញុំ ដូចជាអាវដៃវែងនេះជាដើម។*

ទណ្ឌិតពុំបានទទួលសម្លៀកបំពាក់ ឬ សម្ភារៈអនាម័យដូចជា សាប៊ូដុំ ម្សៅសាប៊ូសម្រាប់បោកគក់ ឬ សំឡីអនាម័យសម្រាប់នារីពីមន្ត្រីពន្ធនាគារទេ ។

កុមាររស់នៅក្នុងពន្ធនាគារជាមួយម្តាយក៏ពុំបានទទួលរបបសម្លៀកបំពាក់ ឬ សម្ភារៈអនាម័យ ដែលបញ្ហានេះ ធ្វើឱ្យមានការលំបាករឹតតែខ្លាំងដល់ម្តាយ និង កុមារ នៅពេលដែលកុមារចាប់ផ្តើមធំលូតលាស់។ កុមារទាំង

នោះពឹងផ្អែកលើការបរិច្ចាកពីកុមារផ្សេងទៀតរបស់ទណ្ឌិតដូចគ្នា ដែលត្រូវបានដោះលែង ពីសំណាក់គ្រួសាររស់នៅក្រៅពន្ធនាគារ និង អង្គការនានាជួយនៅក្នុងផ្នែកនេះ ។

## ការរស់នៅក្នុងពន្ធនាគារជាមួយកូន

*វាជាការលំបាកណាស់ដែលខ្ញុំមានកូនស្រី ម៉ាលី រស់នៅជាមួយខ្ញុំក្នុងពន្ធនាគារនេះ ។ ប្រសិនបើគេចាក់សោខ្ញុំទុកក្នុងបន្ទប់ឃុំឃាំង នោះម៉ាលីក៏ត្រូវជាប់នៅក្នុងនោះដែរ ។ គេកម្រឱ្យម៉ាលីនៅក្រៅបន្ទប់ ទោះបីជានាងពុំមែនជាទណ្ឌិតក៏ដោយ ។ ជួនកាល គេអាចឱ្យនាងទៅសាលារៀនជាមួយកុមារផ្សេងទៀត ដែលរស់នៅក្នុងពន្ធនាគារនេះ និងជាមួយកូនៗរបស់ឆ្មាំពន្ធនាគារដែរ ប៉ុន្តែចំណែកខ្ញុំវិញត្រូវតែនៅក្នុងបន្ទប់ឃុំឃាំងដែលត្រូវចាក់សោជាប់ ។*

*ជាធម្មតា កូនខ្ញុំមិនដែលបានញ៉ាំបាយឆ្អែតទេ ទោះបីជាយើងបានទទួលជំនួយបន្ថែមពីអ្នកឧបត្ថម្ភខាងក្រៅមួយខែពីរដងក៏ដោយ នោះគឺដោយសារនាងរស់នៅជាមួយខ្ញុំ ។ នាងស្រែកឃ្លាន រាល់ពេលដែលនាងឃើញបាយសំរាប់ទណ្ឌិតបរិភោគ ដែលជាបាយពណ៌ស្រអាប់ គ្មានជាតិ ថែមទាំងមិនស្អាតទៀតផង ។ នេះជារឿងលំបាកមែនទែន ។ នៅពេលដែលខ្ញុំឃើញកូនលំបាកក្រៀមក្រំដូច្នេះ ខ្ញុំពិបាកទ្រាំណាស់ ដោយខ្ញុំចង់ឱ្យនាងមានបាយ ម្ហូបអាហារញ៉ាំច្រើនជាងនេះ ដូច្នេះខ្ញុំក៏ជួយដាំស្លឱ្យពួកទណ្ឌិតដទៃៗទៀត ដើម្បីបានបាយខ្លះៗឱ្យម៉ាលីញ៉ាំ ។*

*កូនរបស់ខ្ញុំយល់អំពីរសជាតិនៃការរស់នៅក្នុងពន្ធនាគារ ពីព្រោះនាងចូលមករស់នៅទីនេះតាំងពីតូច ហើយនាងក៏បានធំធាត់ឡើងនៅទីនេះ ។ នាងធ្លាប់និយាយប្រាប់ខ្ញុំថា " ខ្ញុំសង្ឃឹមថា ម៉ាក់ និង ខ្ញុំអាចចេញពីពន្ធនាគារ ហើយយើងមិនត្រឡប់មកទីនេះវិញជាដាច់ខាត ដូច្នេះ យើងអាចរស់នៅជាមួយគ្នាឯខាងក្រៅជារៀងរហូត " ។*

*ខ្ញុំមិនចង់ឱ្យ ម៉ាលី រស់នៅជាមួយខ្ញុំក្នុងពន្ធនាគារនេះរហូតដល់ខ្ញុំផុតការកំណត់ទោសទេ ។ ខ្ញុំមានអារម្មណ៍ភ័យខ្លាចណាស់ ពេលដែលនាងរស់នៅទីនេះជាមួយខ្ញុំ ខ្ញុំបារម្ភខ្លាចក្រែងមានបញ្ហាអាក្រក់ណាមួយកើតឡើងចំពោះនាង ។ ខ្ញុំក៏ព្រួយបារម្ភខ្លាចនាងគ្មានអនាគតល្អ ដោយសារនាងមិនបានរៀនសូត្រ និងខ្លាចក្រែងនាងមិនបានចេញពីពន្ធនាគារទៀតផង ។ ឥឡូវនេះ ខ្ញុំសប្បាយណាស់ដែលនាងបានរស់នៅកន្លែងស្អាតបាត មានបាយញ៉ាំគ្រប់គ្រាន់ មានពេលទៅរៀន ហើយអាចមកលេងខ្ញុំជារៀងរាល់ខែ ។*

កុមាររស់នៅក្នុងពន្ធនាគារជាមួយម្តាយរបស់ពួកគេ ក៏ត្រូវចាត់ទុកថាដូចជាទណ្ឌិតដែរ ។ កុមារទាំងនោះពុំអាចចេញចូលពន្ធនាគារបានតាមចិត្តទេ ហើយក៏មិនត្រូវបានអនុញ្ញាតឱ្យចេញពីបន្ទប់ឃុំឃាំងតែឯកឯង ដោយគ្មានម្តាយចេញជាមួយក្នុងពេលត្រូវចេញក្រៅហាត់ប្រាណឡើយ ។

យោងតាមច្បាប់កម្ពុជា[៨] ចែងថា កុមារអាចរស់នៅជាមួយឪពុកម្តាយរហូតដល់អាយុ ៦ ឆ្នាំ ។ ហេតុនេះហើយបានជាទារក ឬ កុមារតូចជាច្រើនដែលមករស់នៅក្នុងពន្ធនាគារជាមួយឪពុកម្តាយដល់ពេលអាយុ ៦ ត្រូវគេបង្ខំឱ្យចាកចេញ ។

តាមការអនុវត្តជាក់ស្តែង លីកាដូ បានសង្កេតឃើញថា មានកុមារមួយចំនួនត្រូវនៅជាមួយម្តាយរហូតដល់អាយុ ១៣ ក៏មានដែរ ដោយនេះវាជាករណីលើកលែង ហើយបញ្ហានេះ គឺអាស្រ័យលើការសម្រេចចិត្តរបស់ប្រធានពន្ធនាគារតែម្នាក់គត់ ។ ជាទូទៅ នៅពេលដែលកុមារណាម្នាក់មានអាយុគ្រប់ ៦ ឆ្នាំហើយ មន្ត្រីពន្ធនាគារច្រើនតែជម្រុញម្តាយកុមារឱ្យរកកន្លែងដើម្បីកូនរស់នៅ នេះគឺជាការលំបាកមួយចំពោះនារីដែលស្ថិតក្នុងការឃុំឃាំងដែលពុំមានឱកាសទាក់ទងមកខាងក្រៅបាន ។ ហេតុនេះករណីភាគច្រើន កុមារត្រូវបន្តរស់នៅជាមួយម្តាយ ពីព្រោះពុំមានកន្លែងណាដែលគេអាចទៅរស់នៅបាន ។ ក្នុងករណីនេះ លីកាដូ និង អង្គការដៃគូនានា តែងតែព្យាយាមជួយម្តាយ និង កូនក្នុងការស្វែងរកកន្លែងឱ្យកូនរស់នៅក្នុងបរិយាកាសមួយប្រកបដោយសុវត្ថិភាព និង ធានារក្សាទំនាក់ទំនងរវាងម្តាយ និង កូនជាប្រចាំ ។

## អំពើហិង្សាពីសំណាក់មន្ត្រីពន្ធនាគារ

*ខ្ញុំមិនដែលរងគ្រោះដោយអំពើហិង្សាពីសំណាក់មន្ត្រីពន្ធនាគារទេ ដោយខ្ញុំមិនដែលធ្វើអ្វីខុស ខ្ញុំគិតថា ខ្ញុំត្រូវតែធ្វើអ្វីៗដែលខ្ញុំត្រូវធ្វើ ដើម្បីជៀសឱ្យផុតពីការដាក់ទណ្ឌកម្មនានា ។ ប៉ុន្តែ កូនខ្ញុំឧស្សាហ៍ទទួលអំពើហិង្សាពីសំណាក់ឆ្មាំពន្ធនាគារ ។ ពួកឆ្មាំពន្ធនាគារធ្លាប់វាយកូនខ្ញុំ ។ កូនខ្ញុំរត់លេងជាមួយកុមារផ្សេងៗទៀតនៅក្នុងពន្ធនាគារ ហើយពួកឆ្មាំគិតថា ជាការរំខានដល់ពួកគេ ទើបគេវាយកូនខ្ញុំ ។ គេវាយនាងញឹកញាប់ណាស់ ហើយពេលគេវាយម្តងៗ ខ្ញុំភ័យខ្លាចថា មានបញ្ហាអ្វីអាក្រក់កើតឡើងចំពោះនាង ហើយខ្ញុំក៏ស្រែកយំ ។ ខ្ញុំខឹងពួកឆ្មាំទាំងនោះខ្លាំងណាស់ ពេលគេវាយធ្វើបាបកូនខ្ញុំម្តងៗ ។*

*មានអំពើហិង្សាជាច្រើនដែលពួកឆ្មាំពន្ធនាគារបានប្រព្រឹត្តនៅទីនេះ ។ កាលពីពីរបីសប្តាហ៍មុន មាននារីពីរនាក់បានវាយតប់គ្នា ។ នារីម្នាក់បានជួយឃាត់កុំឱ្យវាយតប់គ្នា ប៉ុន្តែពេលដែលឆ្មាំចូលមកដល់ គេក៏បានវាយនារីនោះដោយដំបងរហូតដល់បាក់ដៃគាត់ ។ ក្រោយពីបាក់ដៃ ពេទ្យពន្ធនាគារបានឱ្យគាត់លេបតែថ្នាំប៉ារ៉ាសេតាមុលប៉ុណ្ណោះ គ្មានថ្នាំអ្វីក្រៅពីនេះទេ ។*

*កូនខ្ញុំក៏ធ្លាប់បានឃើញពួកឆ្មាំវាយទណ្ឌិតជាញឹកញាប់ដែរ ។ នាងបានឃើញពួកឆ្មាំវាយទណ្ឌិតបុរសៗ*

---

[៨] កុមារក្រោមអាយុ ៦ ឆ្នាំ ត្រូវបានអនុញ្ញាតឱ្យរស់នៅក្នុងពន្ធនាគារជាមួយឪពុកម្តាយដែលជាប់ឃុំ ក្នុងករណីដែលគិតថា នេះគឺជាវិធីដ៏ល្អសម្រាប់ឧត្តមប្រយោជន៍កុមារ ។ នីតិវិធីពន្ធនាគារលេខ ៣៤ ចែងពី "នារីមានផ្ទៃពោះ និង កុមារក្នុងពន្ធនាគារ" - មាត្រា ៣.២ ។

*ជាញឹកញាប់ដោយប្រើខ្សែក្រវាត់ និងដំបងនៅខាងក្រៅបន្ទប់ក្នុងទីធ្លាពន្ធនាគារ ។*

*ពួកឆ្មាំស្រវឹងស្រាញឹកញាប់ណាស់ ហើយពេលគេស្រវឹងម្ដងៗ គេច្រើនតែវាយទណ្ឌិតបុរសៗ ហើយកូនខ្ញុំបានឃើញការវាយដំនេះញឹកញាប់ណាស់។ ពេលស្រវឹង គេច្រើនតែប្រើទណ្ឌិតឱ្យធ្វើសរសៃឱ្យ ហើយពេលដែលទណ្ឌិតនឿយហត់ខ្ជិលធ្វើសរសៃហើយចង់ឈប់ ពេលនោះឆ្មាំក៏វាយបង្ខំឱ្យធ្វើបន្តទៀត។*

*កូនខ្ញុំ និង ខ្ញុំក៏ធ្លាប់បានឃើញឆ្មាំវាយដំនារីទណ្ឌិតដែរ។ ប្រសិនបើយើងមានការងារត្រូវធ្វើច្រើនដូចជាដាំស្ល ឬ បោកគក់ ឆ្មាំច្រើនតែវាយទណ្ឌិតនារី ប្រសិនបើពួកគេគិតថា នារីទាំងនោះពុំខំប្រឹងធ្វើការទេ ដើម្បីគំរាមពួកយើងឱ្យខំប្រឹងធ្វើការឱ្យលឿនជាងមុន។*

*ខ្ញុំមិនបានដឹងថា មាននារីណាម្នាក់ត្រូវបានពួកឆ្មាំពន្ធនាគាររំលោភសេពសន្ថវៈ ឬរំលោភបំពានផ្លូវភេទទេ ខ្ញុំពុំដែលបានឮបញ្ហានេះកើតឡើងក្នុងពន្ធនាគារទេ ។*



អំពើហិង្សាមកលើទណ្ឌិតនារីពីសំណាក់មន្ត្រីពន្ធនាគារ មិនត្រូវបានរាយការណ៍ជាប់លាប់ឱ្យអ្នកស្រាវជ្រាវលីកាដូទេ ទោះបីជាបញ្ហានេះត្រូវបានសង្ស័យថា ទណ្ឌិតអាចរងគ្រោះដោយអំពើហិង្សា (រួមមានរំលោភបំពានផ្លូវភេទ) និងទារុណកម្មជាដើម។ ក្នុងឆ្នាំ២០០៧ អ្នកស្រាវជ្រាវពន្ធនាគារលីកាដូ បានរាយការណ៍នូវការចោទប្រកាន់ចំនួន ២៩ (បុរស ២៦ នាក់ និង នារី ៣ នាក់) ទាក់ទងនឹងអំពើទារុណកម្ម និងការធ្វើទុក្ខទោសផ្សេងទៀតនៅក្នុងពន្ធនាគារ យោងតាមការសម្ភាសន៍ជាមួយទណ្ឌិត ។

ការធ្វើទុក្ខទោសដល់ទណ្ឌិតក្នុងពន្ធនាគារទំនងជាមិនត្រូវបានរាយការណ៍មកទេ ពីព្រោះទណ្ឌិតភ័យខ្លាចក្នុងការនិយាយអំពីបញ្ហានេះ។ ការសម្ភាសន៍រវាងទណ្ឌិត និង អ្នកស្រាវជ្រាវពន្ធនាគារលីកាដូ ច្រើនតែធ្វើឡើងក្រោមការឃ្លាំមើលយ៉ាងជិតដល់ពីសំណាកមន្ត្រីពន្ធនាគារ ដូច្នេះបញ្ហានេះ វាជាការលំបាកដល់ទណ្ឌិតក្នុងការផ្ដល់ព័ត៌មានអំពីអំពើហិង្សាជាចំហរណាស់ ។

របាយការណ៍ចុងក្រោយបំផុតស្ដីពីអំពើរំលោភសេពសន្ថវៈមកលើទណ្ឌិតនារីម្នាក់គឺនៅឆ្នាំ១៩៩៦។ ករណីធ្ងន់ធ្ងរនេះ កើតឡើងក្នុងពន្ធនាគារខេត្តកោះកុង ដែលបានប្រព្រឹត្តដោយទណ្ឌិតដូចគ្នា មន្ត្រីពន្ធនាគារ និងនាយកពន្ធនាគារ អស់មួយរយៈពេល។ នាយកពន្ធនាគារត្រូវបាត់បង់តួនាទី ប៉ុន្តែពុំបានទទួលទោសទេ ដោយសារតែមាន

អ្នកការពារគាត់។[៥] ចាប់តាំងពីពេលនោះមក ពុំមានករណីណាមួយបញ្ជាក់ឱ្យបានច្បាស់លាស់អំពីករណីរំលោភសេពសន្ថវៈ ឬ រំលោភបំពានផ្លូវភេទនៅក្នុងពន្ធនាគារទេ ប៉ុន្តែនៅតែមានការចោទប្រកាន់ដោយគ្មានភស្តុតាងថា មានការរំលោភសេពសន្ថវៈដោយមន្ត្រីពន្ធនាគារ។

នារីមួយចំនួនមានផ្ទៃពោះក្នុងពេលជាប់ពន្ធនាគារ ។ ប្រហែលជាករណីខ្លះក្នុងចំណោមករណីទាំងនេះ ការរួមភេទប្រព្រឹត្តទៅដោយមានការព្រមព្រៀងគ្នា ប៉ុន្តែ លីកាដូសង្ស័យថា មាននារីមួយចំនួនអាចត្រូវបានគេរំលោភ-សេពសន្ថវៈ ឬ ត្រូវបានគេបង្ខំ ឬ ទាក់ទាញទឹកចិត្តឱ្យព្រមរួមភេទ ដើម្បីទទួលផលប្រយោជន៍ពីមន្ត្រីពន្ធនាគារ។

អំពើហិង្សាលើកុមារ គឺមិនអាចទទួលយកបានឡើយ ហើយថែមទាំងជាការរំលោភលើសិទ្ធិជាមូលដ្ឋានរបស់កុមារទៀតផង។ គ្មានកាលៈទេសៈណាមួយដែលមន្ត្រីពន្ធនាគារអាចប្រព្រឹត្តអំពើហិង្សាលើកុមារបានទេ ជាពិសេសកុមារទាំងឡាយដែលរស់នៅក្នុងពន្ធនាគារជាមួយម្តាយ ដែលសន្មតថាស្ថិតក្រោម "ការថែទាំ" របស់ពន្ធនាគារ ។

ការបានឃើញផ្ទាល់ និងបទពិសោធន៍ទទួលរងអំពើហិង្សារបស់កុមារជាប្រចាំបែបនេះ គឺជាគ្រោះថ្នាក់ដល់ការធំលូតលាស់របស់កុមារ ។

## អំពើហិង្សាពីសំណាក់ទណ្ឌិតដូចគ្នា

*ពេលខ្លះ នារីមួយចំនួននៅក្នុងបន្ទប់ឃុំឃាំងជាមួយមានការខឹងជាមួយកូនខ្ញុំ ព្រោះនាងចូលចិត្តនិយាយឡូឡាច្រើន ហើយពួកស្ត្រីទាំងនោះត្រូវការភាពស្ងៀមស្ងាត់ ប៉ុន្តែពួកគេពុំធ្លាប់មាននរណាវាយកូនខ្ញុំទេ ហើយក៏ពុំដែលមាននរណាម្នាក់វាយខ្ញុំដែរ ដោយខ្ញុំតែងតែព្យាយាមកុំឱ្យមានបញ្ហាកើតឡើង ។*

អំពើហិង្សាកើតឡើងរវាងទណ្ឌិតដូចគ្នា គឺជាបញ្ហាកើតឡើងជាធម្មតាបំផុតនៅក្នុងប្រទេសកម្ពុជា ដោយសារស្ថានភាពចង្អៀតខ្លាំងក្នុងបន្ទប់ឃុំឃាំង ការដណ្តើមអំណាច ការច្រណែនគ្នា ការដណ្តើមម្ហូបអាហារ សម្ភារៈ និង បញ្ហាផ្សេងៗជាដើម។

កន្លងមកក៏មានសេចក្តីរាយការណ៍ថា ទណ្ឌិតធ្លាប់បានប្រព្រឹត្តអំពើហិង្សាមកលើកុមារដែលរស់នៅក្នុងបន្ទប់ឃុំឃាំងពន្ធនាគារដែរ ។

[៥] របាយការណ៍លីកាដូ: ពន្ធនាគារកម្ពុជា ១៩៩៧ ទំ. ១២។

## ការប្រព្រឹត្តិរបស់មន្ត្រីពន្ធនាគារចំពោះកូនខ្ញុំ និង ភ្ញៀវនានា

*លោកនាយកពន្ធនាគារ និង ឆ្មាំទាំងអស់មិនចង់ឱ្យកូនខ្ញុំរស់នៅជាមួយខ្ញុំក្នុងពន្ធនាគារទេ ។ គេតែងតែប្រាប់ខ្ញុំជាប្រចាំថា ម៉ាលីមិនគួររស់នៅក្នុងពន្ធនាគារជាមួយខ្ញុំទេ ហើយនិយាយបន្ថែមថា ខ្ញុំគួរតែរកអង្គការណាមួយឱ្យជួយថែរក្សានាងទៅ ។*

*ឥឡូវនេះ កូនខ្ញុំបានចេញផុតពីពន្ធនាគារ ហើយកំពុងរស់នៅក្នុងផ្ទះថ្មីមួយ ហើយនាងបានមកលេងខ្ញុំ ។ នាងបានមកលេងពីរបីដងដែរ ប៉ុន្តែពួកឆ្មាំមិនឱ្យនាងចូលមកលេងខ្ញុំទេ ពីព្រោះនាងពុំមានប្រាក់កាសបង់ឱ្យពួកគេ ។ តើនាងត្រូវធ្វើយ៉ាងម៉េច ដើម្បីឱ្យមានប្រាក់កាសបាន បើនាងនៅវ័យក្មេងបែបនេះ ។*

*ឥឡូវនេះ យើងអាចឃើញពួកទណ្ឌិតមួយចំនួន ត្រឡប់មកពីជួបបងប្អូនរបស់គេវិញហើយ ។ ខ្ញុំជឿជាក់ថា បងប្អូន ឬ សាច់ញាតិរបស់ពួកគេប្រាកដជាបង់ប្រាក់កាសច្រើនហើយ ទើបបានការអនុញ្ញាតចូលមកសួរសុខទុក្ខ ។ ពេលនេះអ្នកអាចឃើញ ពួកគេបានម្ហូបអាហារយ៉ាងច្រើនដែលបងប្អូនគេយកមកផ្ញើ ហើយអ្នកអាចមើលឃើញពួកឆ្មាំពន្ធនាគារកំពុងតែដកហូតយកម្ហូបអាហារទាំងនោះ មើលហ្ន៎! គេកំពុងពិនិត្យមើលក្នុងថង់របស់ពួកទណ្ឌិត ហើយគេដកយកសំភារៈមួយផ្នែកធំ ។ គាត់ទុកឱ្យទណ្ឌិតដែលជាម្ចាស់ម្ហូបអាហារនោះតែបន្តិចបន្តួចប៉ុណ្ណោះ ។ ខ្ញុំជឿជាក់ថា ម្ដាយរបស់ទណ្ឌិតនោះ ពុំបានដឹងរឿងនេះទេ ហើយឆ្មាំពន្ធនាគារនោះកំពុងសើចកំប្លែងលេងបែបជាធម្មតារបស់គេទៅហើយ ពីព្រោះនៅទីនេះ បញ្ហាបែបនេះវាកើតឡើងគ្រប់ពេលទាំងអស់ ។*

*ពួកឆ្មាំពន្ធនាគារ មិនដែលដកហូតយកចំណីអាហារដែលជាអំណោយរបស់ខ្ញុំ ឬ កូនខ្ញុំទេ ប៉ុន្តែបញ្ហានេះខ្ញុំគិតថា ពីព្រោះគេដឹងថា មានអង្គការតាមឃ្លាំមើលពួកគេយ៉ាងដិតដល់ ។*

ដើម្បីឱ្យក្រុមគ្រួសារបានចូលសួរសុខទុក្ខទណ្ឌិតក្នុងពន្ធនាគារ ពួកគេត្រូវចំណាយថវិកាឱ្យមន្ត្រីពន្ធនាគារ ។ សំណូកនេះអាចមានចាប់ពី ២000 រៀល (0.៥0ដុល្លារ) រហូតដល់រាប់រយដុល្លារ អាស្រ័យទៅតាមមន្ត្រីពន្ធនាគារនីមួយៗ និង មើលទៅថាគ្រួសារនោះធូរធា ឬ ខ្វះខាត ។

គ្រួសារ និង ភ្ញៀវត្រូវបានគេបដិសេធមិនឱ្យចូលជួបមនុស្សជាទីស្រឡាញ់របស់គេទេ ប្រសិនបើពុំមានលទ្ធភាពបង់ឱ្យមន្ត្រីពន្ធនាគារទេ ។

ជាញឹកញាប់ ទោះបីជាការសូកប៉ាន់ក្តី ក៏ការសាកសួរសុខទុក្ខនោះត្រូវបានមន្ត្រីពន្ធនាគារឃ្លាំមើល ហេតុនេះ




ទណ្ឌិតអាចមានការភ័យខ្លាច មិនហ៊ានប្រាប់បងប្អូនអំពីស្ថានភាពពិតប្រាកដនៅក្នុងពន្ធនាគារទេ ។ មន្ត្រីពន្ធនាគារតែងតែដកហូតយកចំណីអាហារ សម្ភារៈអនាម័យភាគច្រើន ដែលបងប្អូនបានយកមកផ្ញើ។ ក្រុមគ្រួសារពួកគេ មិនដែលដឹងអំពីរឿងទាំងនេះទេ ហើយនៅតែបន្តនាំយករបស់របរទាំងនោះ ទៅកាន់ពន្ធនាគារដដែល ។

## រស់នៅក្នុងពន្ធនាគារជាមួយ ម៉ាលី : ចំណុចល្អ និង អាក្រក់

*ពួកទណ្ឌិតភាគច្រើនចូលចិត្តកូនខ្ញុំ ដោយនាងជាកុមារីឆ្លាត ហើយចេះនិយាយលេង និង គួរសមជាមួយទណ្ឌិតផ្សេងៗទៀត ។ នាងជាកុមារីសុភាពរាបសារ ។*

*ចំណុចល្អបំផុតដែលម៉ាលីរស់នៅជាមួយខ្ញុំក្នុងពន្ធនាគារមានដូចជា បើខ្ញុំអាចរស់នៅជាមួយនាងរយៈពេលពីរបីឆ្នាំទៀត នោះខ្ញុំអាចធ្វើជាម្តាយ និងមើលថែទាំនាងអស់ពីលទ្ធភាពដែលខ្ញុំអាចធ្វើទៅបាន ។ ហើយខ្ញុំក៏សប្បាយចិត្តដែរ ដែលនាងអាចរៀនសូត្រភាសាខ្មែរបានខ្លះៗពីទណ្ឌិតដទៃៗទៀត ។*

*ចំណែកឯចំណុចអាក្រក់ដែលម៉ាលីរស់នៅក្នុងពន្ធនាគារជាមួយខ្ញុំវិញ គឺមានដូចជា នៅទីនេះគេប្រព្រឹត្តចំពោះនាងដូចជាទណ្ឌិតម្នាក់ដែរ ។ នាងតែងតែជាប់នៅខាងក្នុងបន្ទប់ឃុំឃាំង ហើយគ្មានសេរីភាពទេ ។ នាងមិនត្រូវបានអនុញ្ញាតឱ្យលេងដូចកុមារជាប្រក្រតីទេ ហើយខ្ញុំយល់ថា នាងពុំមានឱកាស ដើម្បីទទួលបានអនាគតល្អឡើយ ។*

កាលពីមុន លីកាដូធ្លាប់បានធ្វើការស្រាវជ្រាវ[១០] បង្ហាញឱ្យឃើញថា ដោយមានការគាំទ្រ ម្តាយ និង កុមារអាចបន្តទំនាក់ទំនងយ៉ាងល្អ ខណៈពេលរស់នៅក្នុងពន្ធនាគារ ហើយការបន្តទំនាក់ទំនងនេះ គឺផ្តល់ផលប្រយោជន៍ព្រមទាំងសារៈសំខាន់សម្រាប់សុខមាលភាពរបស់ម្តាយ និង កូន ។ ជារឿយៗ ទំនាក់ទំនងរវាងម្តាយ និង កូនកាន់តែល្អឡើង ដោយម្តាយមានពេលទំនេរច្រើនពុំមានកូនផ្សេងទៀត ឬ កាតព្វកិច្ចខាងក្រៅណាមួយមករំខានពីការថែទាំ

[១០] កុមារក្នុងពន្ធនាគារជាមួយម្តាយ ( ជែន ម៉ាគិន- របាយការណ៍ផ្ទៃក្នុងលីកាដូ ខែកញ្ញា ឆ្នាំ២០០៥) និង ការវាយតម្លៃគម្រោងផ្តល់ជំនួយម្ហូបអាហារដល់កុមារ និង នារីមានផ្ទៃពោះក្នុងពន្ធនាគារ ដោយមេហ្គាន់ វីឆាដសុន — របាយការណ៍ផ្ទៃក្នុងលីកាដូ ខែឧសភា ឆ្នាំ២០០៥) ។

កូនឡើយ។ ការរស់នៅក្នុងពន្ធនាគារអាចជួយឱ្យចំណងទំនាក់ទំនងរវាងម្តាយ និង កូនកាន់តែរឹងមាំថែមទៀត និងបង្កឱ្យមានភាពជិតស្និទ្ធកាន់តែខ្លាំងឡើងថែមទៀត។

ទោះបីជាមានអត្ថប្រយោជន៍ពិតប្រាកដ ចំពោះការអនុញ្ញាតឱ្យកុមាររស់នៅក្នុងពន្ធនាគារជាមួយម្តាយក៏ដោយ ការពិតកុមារតូចៗដែលរស់នៅជាមួយម្តាយក្នុងពន្ធនាគារនៅតែប្រឈមមុខនឹងគ្រោះថ្នាក់ និង ភាពតានតឹងដែលអាចប៉ះពាល់ដល់សុខភាព និង ការលូតលាស់ ។ ប្រសិនបើមានការកែលំអស្ថានភាពពន្ធនាគារ និង មានការគាំទ្របន្ថែម នោះផលវិបាកបណ្តាលមកពីបញ្ហានេះ អាចនឹងត្រូវបានកាត់បន្ថយជាអប្បបរមា ។

## សម្តីចុងក្រោយរបស់ លីណា

*ពេលខ្លះ ដូចជាករណីខ្ញុំជាដើម គឺចាំបាច់ណាស់ចំពោះម្តាយក្នុងការនាំយកកូនៗ មករស់នៅជាមួយខ្លួនក្នុងពន្ធនាគារ ។ ខ្ញុំគិតថា រដ្ឋាភិបាល និង អង្គការមូលនិធិមួយចំនួន ត្រូវផ្តល់ថវិកាសម្រាប់ម្ហូបអាហារ សម្លៀកបំពាក់ ការថែទាំផ្នែកសុខភាព និង ការអប់រំដល់ទណ្ឌិតថែមទៀត។ ប៉ុន្តែខ្ញុំគិតថា នៅទីណាដែលមានកុមារ រដ្ឋាភិបាល និង អង្គការមូលនិធិទាំងឡាយ ត្រូវកសាងកន្លែងសុវត្ថិភាពសម្រាប់កុមារទាំងឡាយរស់នៅក្នុងពន្ធនាគារ កសាងសាលាដែលកុមារអាចរៀនសូត្របាន ព្រមទាំងផ្តល់ម្ហូបអាហារបន្ថែមដល់កុមារ។ ការរៀបចំបែបនេះ នោះនឹងលែងមានកុមារណាម្នាក់ស្រែកឃ្លាន ដោយសារស្រែកឃ្លានចំណីអាហាររៀងរាល់យប់ទៀតហើយ ។*



# ៣. ជីវិតរស់នៅក្នុងពន្ធនាគារៈ រឿងរបស់កុមារីម្នាក់

## រឿងរបស់ម៉ាលី

***ការទៅពន្ធនាគារ***

*ខ្ញុំឈ្មោះ ម៉ាលី ខ្ញុំធ្លាប់រស់នៅក្នុងពន្ធនាគារជាមួយម្ដាយខ្ញុំ ។ ខ្ញុំរស់នៅក្នុងពន្ធនាគារអស់រយៈពេលពីរបីឆ្នាំ ពីព្រោះពេលដែលខ្ញុំទៅដល់ពន្ធនាគារមុនដំបូង ខ្ញុំនៅតូចនៅឡើយ ។ ខ្ញុំពុំបានដឹងថា ហេតុអ្វីបានជាម្ដាយខ្ញុំ ត្រូវទៅពន្ធនាគារទេ ប៉ុន្តែគាត់ប្រាប់ខ្ញុំថា គាត់ត្រូវតែយកខ្ញុំទៅជាមួយ ព្រោះគាត់ជាម្ដាយខ្ញុំ ហើយគាត់មានភារៈថែរក្សាខ្ញុំ ។*

***ការរស់នៅក្នុងបន្ទប់ឃុំឃាំង***

*ខ្ញុំរស់នៅក្នុងបន្ទប់ឃុំឃាំងជាមួយម្ដាយខ្ញុំ និងនារីជាច្រើននាក់ទៀត ហើយមានតែខ្ញុំម្នាក់គត់ជាកុមារនៅក្នុងបន្ទប់នោះ ។ មានកុមារផ្សេងទៀតរស់នៅក្នុងពន្ធនាគារដែរ ប៉ុន្តែនៅកន្លែងផ្សេង ហើយពួកគេខ្លះគឺជាមិត្តភ័ក្ដរបស់ខ្ញុំ ។ តាមពិតទៅ ខ្ញុំមិនចូលចិត្តរស់នៅក្នុងពន្ធនាគារទេ ។ ខ្ញុំពិបាកគេងណាស់នៅក្នុងនោះ កំរាលឥដ្ឋមិនស្អាត ហើយចង្អៀតជាខ្លាំង ហើយម្ដាយខ្ញុំមិនឱ្យខ្ញុំគេងនៅលើឥដ្ឋផ្ទាល់ទេ ។ រៀងរាល់យប់ មុនពេលខ្ញុំចូលគេង ម្ដាយខ្ញុំយកធុងទទេមួយចំនួន ដូចជាធុងទឹកធំៗគ្មានទឹកជាដើម ដាក់តម្រៀបគ្នាឱ្យខ្ញុំគេងពីលើធុងទាំងនោះ ខ្ញុំគេងអត់ស្រួលទេ ។ ខ្ញុំមិនដឹងថា កុមារផ្សេងទៀតក្នុងពន្ធនាគារគេងបែបនេះដែរឬអត់ទេ ពីព្រោះមានតែខ្ញុំម្នាក់គត់ជាកុមាររស់នៅក្នុងបន្ទប់នោះ ។*

***ទឹក និង ចំណីអាហារ***

*រៀងរាល់ថ្ងៃ ខ្ញុំឃ្លានបាយខ្លាំងណាស់ អ្នកធ្វើការក្នុងពន្ធនាគារនោះ ឱ្យបាយខ្ញុំញ៉ាំតែពីរចានទេក្នុងមួយថ្ងៃ ជួនកាលសម្លមានទឹកច្រើន រាវៗនៅក្នុងបាយនោះ និង មានបន្លែតិចតួចតែប៉ុណ្ណោះ ដែលខ្ញុំត្រូវញ៉ាំចែករំលែកជាមួយម្ដាយខ្ញុំ ។ ប៉ុន្តែមានពេលខ្លះ ខ្ញុំក៏បានចំណីអាហារលើសពីនេះដែរ ខ្ញុំមិនដឹងថា អ្នកណាឱ្យចំណីអាហារទាំងនោះទេ ប៉ុន្តែម្ដាយខ្ញុំ និង ខ្ញុំបានចំណីអាហារបែបនេះ និង អ្វីៗផ្សេងទៀតច្រើនដែរ ។ ពេលខ្លះ ខ្ញុំបានឃើញអ្នកធ្វើការក្នុងពន្ធនាគារយកចំណីអាហារពីអ្នកដទៃ ប៉ុន្តែចំណែកខ្ញុំវិញ គេមិនដែលយករបស់ខ្ញុំទេ ខ្ញុំកាន់វាយ៉ាងជាប់ ហើយឱ្យទៅម្ដាយខ្ញុំទុក ។ ម្ដាយខ្ញុំអត់មានលុយទេ ដូច្នេះហើយគាត់មិនដែលទិញទឹកឱ្យខ្ញុំញ៉ាំទេ ខ្ញុំត្រូវតែញ៉ាំ*

*ទឹកកខ្វក់នោះ ហើយរាល់ពេលខ្ញុំញ៉ាំវាទៅ វាធ្វើឱ្យខ្ញុំក្អក ហើយឈឺទៀតផង ។*

### ***រស់នៅក្នុងពន្ធនាគារជាមួយម្តាយខ្ញុំ***

*រស់នៅក្នុងពន្ធនាគារលំបាកណាស់សម្រាប់ខ្ញុំ ជាពិសេសនៅពេលដែលខ្ញុំធំឡើង ។ ខ្ញុំមានអារម្មណ៍ព្រួយយ៉ាងខ្លាំង ពីព្រោះខ្ញុំមិនអាចចេញទៅក្រៅបានទេ ពេលណាខ្ញុំចង់ចេញ ហើយគេចាក់សោជាប់ឱ្យខ្ញុំនៅក្នុងបន្ទប់ជាមួយម្តាយរបស់ខ្ញុំ និង នារីផ្សេងទៀតជាច្រើន ។*

*ខ្ញុំមិនចូលចិត្តការរស់នៅបែបនេះសោះ ដោយខ្ញុំមិនដែលបានបាយញ៉ាំគ្រប់គ្រាន់ទេ ហើយក៏មិនដែលមានសាប៊ូដុសសំអាតខ្លួនដែរ ។ ខ្ញុំមានខោអាវតែពីរកំប្លេតែប៉ុណ្ណោះ ហើយម្តាយខ្ញុំតែងតែបោកគក់ឱ្យខ្ញុំ ហើយគ្មានសាប៊ូបោកគក់ទេ ។*

### ***អំពើហិង្សាពីសំណាក់មន្ត្រីពន្ធនាគារ***

*ពេលខ្លះខ្ញុំភ័យយ៉ាងខ្លាំង ជាពិសេសពេលដែលខ្ញុំឃើញអ្នកធ្វើការក្នុងពន្ធនាគារវាយពួកទណ្ឌិត ។ ខ្ញុំបានឃើញអ្នកធ្វើការក្នុងពន្ធនាគារនោះ យកកាំបិតកាត់សាច់ពួកទណ្ឌិតជាការដាក់ទណ្ឌកម្ម ពីព្រោះខ្ញុំគិតថា ទណ្ឌិតទាំងនោះបានវាយតប់គ្នាឯង ហើយខ្ញុំក៏ធ្លាប់ឃើញអ្នកធ្វើការនោះ ដោះខ្សែក្រវាត់ វាយទណ្ឌិតដែរ ។ ខ្ញុំបានឃើញឈាមច្រើនហូរចេញពីខ្លួនពួកទណ្ឌិត ខ្ញុំស្គាល់កុមារជាច្រើន ដែលធ្លាប់បានឃើញទង្វើបែបនេះដូចខ្ញុំដែរ ។ នៅពេលដែលមានរឿងបែបនេះកើតឡើង ម្តាយខ្ញុំ និង មនុស្សដទៃទៀតបោកខ្លួនទៅដី ស្រែកយំ ហើយទាំងអស់គ្នាខឹងពួកឆ្មាំពន្ធនាគារយ៉ាងខ្លាំង ។*

*ខ្ញុំមិនដែលឃើញឆ្មាំពន្ធនាគារវាយអ្នកម្តាយខ្ញុំ ឬ នារីផ្សេងៗដែលនៅជាមួយខ្ញុំ ដូចដែលខ្ញុំធ្លាប់បានឃើញគេវាយអ្នកដទៃទេ ហើយពួកគេក៏មិនដែលវាយកុមារៗដែលរស់នៅក្នុងពន្ធនាគារដូចនោះដែរ ។*

### ***ការចេញពីពន្ធនាគារ***

*ខ្ញុំមិនចាំថា ខ្ញុំបានរស់នៅក្នុងពន្ធនាគារអស់រយៈពេលប៉ុន្មានទេ ប៉ុន្តែ ខ្ញុំមានអារម្មណ៍ថា ខ្ញុំបានរស់នៅអស់រយៈពេលដ៏យូរ ។ បន្ទាប់ពីបានរស់នៅអស់មួយរយៈ ខ្ញុំកាន់តែធំ ហើយពួកអ្នកធ្វើការក្នុងពន្ធនាគារតែងតែនិយាយប្រាប់ម្តាយខ្ញុំថា ឈប់ឱ្យខ្ញុំរស់នៅទីនោះទៀតទៅ រកកន្លែងណារស់នៅផ្សេងពីនេះ ប៉ុន្តែ ម្តាយខ្ញុំចេះតែនិយាយប្រាប់ពួកគេវិញថា នៅខាងក្រៅពន្ធនាគារ គ្មាននរណាជួយមើលថែទាំខ្ញុំទេ ។ ហើយខ្ញុំក៏មិនចង់ចេញទៅណាឆ្ងាយពីម្តាយខ្ញុំដែរ ។*

*ថ្ងៃមួយ មានគេប្រាប់ខ្ញុំថា ខ្ញុំត្រូវតែលាម្ដាយខ្ញុំ ទៅរស់នៅកន្លែងណាផ្សេងឆ្ងាយហើយ ។ គេអត់ប្រាប់ខ្ញុំថា ទៅនៅកន្លែងណាទេ ប៉ុន្តែគេសន្យាជាមួយខ្ញុំថា ខ្ញុំអាចមកលេងម្ដាយខ្ញុំបានម្ដងម្កាល ។*

***សម្ដីចុងក្រោយរបស់ម៉ាលី***

*ឥឡូវនេះ ខ្ញុំរស់នៅក្នុងផ្ទះថ្មី ហើយខ្ញុំសប្បាយចិត្តណាស់ ដែលខ្ញុំមិនរស់នៅក្នុងពន្ធនាគារតទៅទៀត ។ ប៉ុន្តែ ខ្ញុំនឹកម្ដាយខ្ញុំណាស់ ហើយពេលខ្ញុំទៅលេងកាលមុន គាត់យំឱបខ្ញុំ គាត់ថានឹកខ្ញុំខ្លាំងណាស់ ហើយអញ្ចឹងខ្ញុំក៏យំខ្សឹកខ្សួលក្នុងចិត្តដែរ ។*

*ឥឡូវនេះខ្ញុំបានទៅសាលារៀន ខ្ញុំមានមិត្តភ័ក្តថ្មីៗថែមទៀត ហើយមានបាយញ៉ាំគ្រប់គ្រាន់ ។ ខ្ញុំនឹកម្ដាយ និង មិត្តភ័ក្តខ្ញុំនៅក្នុងពន្ធនាគារដែរ ប៉ុន្តែខ្ញុំសប្បាយចិត្តខ្លាំងណាស់ដែលខ្ញុំមិនបានរស់នៅក្នុងពន្ធនាគារដូចមុនទៀត ។*

## អំពើហិង្សាក្នុងពន្ធនាគារ

វាជាបញ្ហាមួយមិនអាចទទួលយកបានទេ ដែលកុមាររស់នៅក្នុងពន្ធនាគារបានទទួលអំពើហិង្សា ហើយក្នុងករណីខ្លះ ពួកគេបានឃើញការធ្វើទារុណកម្មលើទណ្ឌិតផ្សេងទៀត ។

សុវត្ថិភាព និង សុខមាលភាពរបស់កុមាររស់នៅក្នុងពន្ធនាគារត្រូវតែរក្សាឱ្យបាន ហើយគួរផ្ដល់ឱ្យមានបរិយាកាសសុខសាន្តដល់កុមារទាំងឡាយដែលរស់នៅក្នុងពន្ធនាគារ ។

## គំរប់អាយុដែលមិនអាចរស់នៅក្នុងពន្ធនាគារ

កុមារជាច្រើនឈានដល់គំរប់អាយុ ដែលមិនអាចអនុញ្ញាតឱ្យរស់នៅក្នុងប្រព័ន្ធពន្ធនាគារបានទៀតឡើយ ក្នុងពេលដែលកំពុងរង់ចាំម្ដាយរបស់គេជាប់ឃុំបណ្ដោះអាសន្ន ដើម្បីរង់ចាំការកាត់ក្ដី ឬ កំពុងបម្រើទោសក្នុងពន្ធនាគារ ។

ករណីខ្លះ កុមារអាចរកកន្លែងរស់នៅបានជាមួយសាច់ញាតិ គ្រួសារមិត្តភក្តិ ឬ អ្នកជិតខាងក្នុងសហគមន៍របស់ពួកគេ ។

ករណីផ្សេងទៀត ការថែរក្សាកុមារជាអចិន្ត្រៃយ៍ ត្រូវបានធ្វើឡើងដោយអង្គការមិនមែនរដ្ឋាភិបាល ជាពិសេស ក្នុងករណីដែលមានម្ដាយត្រូវជាប់ឃុំឃាំងរហូតដល់កុមារមានអាយុ១៨ ឆ្នាំ ។

ចំណែក លីកាដូ បានព្យាយាមធ្វើការយកចិត្តទុកដាក់តាមដានកុមារដែលបានចាកចេញពីពន្ធនាគារ ជួនកាលជួយផ្ដល់ថវិកា ម្ហូបអាហារ និង ជួយដល់ការអប់រំ ព្រមទាំងជម្រុញឱ្យមានការទំនាក់ទំនងជាប្រចាំរវាង ម្ដាយ និង កុមារជាកូន ។ បញ្ហានេះ ជួនកាលលំបាកក្នុងការតាមរកកុមារ ដោយកុមារពេលធំទៅ ផ្លាស់ប្ដូរទីកន្លែងរស់នៅ និង ទៅស្នាក់នៅកន្លែងផ្សេងៗទៀតជាដើម ។

នៅទីណាដែលលីកាដូបានចូលរួមជាមួយការចាកចេញរបស់កុមារពីពន្ធនាគារ គេតែងតែធ្វើកិច្ចព្រមព្រៀងមួយរវាងពន្ធនាគារ ម្ដាយ អ្នកថែទាំកុមារថ្មី និង លីកាដូ ដើម្បីធានាឱ្យមានសុវត្ថិភាពដល់កុមារ និង រក្សាឱ្យមានការទាក់ទងជាប្រចាំរវាងម្ដាយ និង កូន ។



□□□

# ៤. គម្រោងផ្តល់ជំនួយម្ហូបអាហារដល់កុមារ និងនារីមានផ្ទៃពោះក្នុងពន្ធនាគារ

គម្រោងផ្តល់ជំនួយម្ហូបអាហារដល់កុមារ និង នារីមានផ្ទៃពោះក្នុងពន្ធនាគាររបស់លីកាដូ ចាប់ផ្តើមឡើងក្នុងឆ្នាំ២០០៣ ដើម្បីប្រមែប្រមូល និង សម្របសម្រួលសម្ភារៈ និង ថវិកាជំនួយដល់កុមារ ម្តាយរបស់កុមារ និង នារីមានផ្ទៃពោះរស់នៅក្នុងពន្ធនាគារ ។ ចាប់តាំងពីឆ្នាំ២០០៣មក លីកាដូបានជួយកុមារ និង ឪពុកម្តាយកុមារចំនួនជាង ១១០ នាក់ នូវជំនួយម្ហូបអាហារ សម្ភារៈ សេវាពេទ្យ និង សម្ភារៈជាទំនិញផ្សេងៗទៀតជាប្រចាំ។ ក្រោមការជួយជ្រោមជ្រែងពីអង្គការដៃគូ និងសប្បុរសជននានាទាំងក្នុង និងក្រៅប្រទេស កុមារ និង នារីទាំងនេះបានទទួលការជួយឧបត្ថម្ភយ៉ាងសមល្មម។ បើគិតត្រឹមថ្ងៃចេញផ្សាយរបាយការណ៍នេះ ក្នុងខែមិនា ឆ្នាំ២០០៨ គ្រប់កុមារទាំងអស់ ដែលរស់នៅជាមួយឪពុកម្តាយក្នុងពន្ធនាគារ និង គ្រប់នារីមានផ្ទៃពោះរស់នៅក្នុងពន្ធនាគារ ដែលឃ្លាំមើលដោយអង្គការលីកាដូ ទទួលបានការឧបត្ថម្ភម្ហូបអាហារ និង សម្ភារៈជាប្រចាំក្រោមជំនួយរបស់គំរោងនេះ ។ ទណ្ឌិតមួយចំនួន ទទួលអំណោយរៀងរាល់ពីរសប្តាហ៍ម្តង ចំណែកឯអ្នកផ្សេងទៀតទទួលបានអំណោយម្តងក្នុងមួយខែ។



ពេញមួយរយៈពេលនៃគម្រោងផ្តល់ជំនួយម្ហូបអាហារដល់កុមារ និង នារីមានផ្ទៃពោះក្នុងពន្ធនាគារ (ជំហ៊ានទី១) លីកាដូបានសង្កេតឃើញ កុមារមានការធំធាត់ ឈ្នះជម្ងឺកង្វះជីវជាតិ និង ជម្ងឺផ្សេងៗទៀតជាដើម ព្រមទាំងរួចជីវិតពីលក្ខខណ្ឌរស់នៅដ៏លំបាកលំបិន។

### *គម្រោងផ្តល់ជំនួយម្ហូបអាហារដល់កុមារ និង នារីមានផ្ទៃពោះក្នុងពន្ធនាគារ ជំហ៊ានទី២*

ក្នុងខណៈដែលអំណោយសប្បុរសធម៌របស់អង្គការ និង សប្បុរសជនជាច្រើនបាននាំមកនូវប្រយោជន៍ដល់កុមារហើយក្តី ក៏ពួកគេនៅតែត្រូវការជំនួយយ៉ាងច្រើនដែរ ដើម្បីធានាឱ្យកុមារទាំងនោះមានឱកាសទទួលបានអនាគតល្អ។ ចាប់តាំងពីគម្រោងបានចាប់ផ្តើម លីកាដូបានរៀបចំផែនការអនុវត្តជំហ៊ានទី២ទៀត។ ជំហ៊ាននេះមានគោលបំណងដើម្បីផ្តល់នូវ ៖

- ឱកាសអប់រំ (ដូចជាថ្នាក់រៀនអក្សរ និង ថ្នាក់ថែទាំងសុខភាពនៅមុន និង ក្រោយពេលសម្រាលកូន) សម្រាប់កុមារ និង នារី ។
- ការពិនិត្យសុខភាពជាប្រចាំ រួមមានការចាក់ថ្នាំបង្ការដល់កុមារ (បច្ចុប្បន្នត្រូវបានផ្តល់ដោយរដ្ឋាភិ-បាលកម្ពុជា ប៉ុន្តែពុំបានធ្វើឱ្យបានទៀងទាត់ជាមួយកុមារដែលកើត និង រស់នៅក្នុងពន្ធនាគារទេ) ។
- បរិយាកាសរស់នៅក្នុងបរិវេណពន្ធនាគារប្រកបដោយសុវត្ថិភាព ។
- មានទឹកស្អាតពិសាគ្រប់គ្រាន់ ព្រមទាំងមានបន្ទប់ទឹកស្អាត។
- ម្ហូបអាហារដែលមានជីវជាតិគ្រប់គ្រាន់ បីពេលក្នុងមួយថ្ងៃ ។

លើសពីនេះទៀតជំហ៊ានទី២នេះ នឹងជួយឱ្យកុមារមានឱកាសលេងកំសាន្តជាមួយគ្នានៅក្នុងទីធ្លាដែលមានសុវត្ថិភាពក្នុងបរិវេណពន្ធនាគារ ។ កុមារក៏ត្រូវបាននាំឱ្យមានទំនាក់ទំនាក់ជាមួយជីវភាពរស់នៅខាងក្រៅពន្ធនាគារដែរ ឧទាហរណ៍មានមនុស្សណាម្នាក់ដែលអាចទុកចិត្តបាន ជូនកុមារធំៗចេញពីពន្ធនាគារ ដើម្បីទៅលេងក្រុមគ្រួសាររបស់គេ និង ទស្សនាកន្លែងផ្សេងៗដូចជា ផ្សារ វត្តអារ៉ាម និង វាលស្រែជាដើម។ [១១]

ការបង្កើនទំនាក់ទំនងជាមួយគ្រួសារជាគោលបំណងមួយដ៏សំខាន់ ដើម្បីឱ្យកុមាររស់នៅក្នុងពន្ធនាគារបានទៅជួបក្រុមគ្រួសាររបស់គេនៅខាងក្រៅ ហើយកុមាររស់នៅខាងក្រៅក៏អាចមកជួបឪពុកម្តាយរបស់គេនៅក្នុងពន្ធនាគារផងដែរ។ ត្រូវរៀបចំឱ្យកុមារបានចូលសួរសុខទុក្ខឪពុកម្តាយនៅក្នុងពន្ធនាគារជាប្រចាំ និង រៀបចំឱ្យកុមារក្នុងពន្ធនាគារ បានចំណាយពេលជាមួយគ្រួសាររបស់ពួកគេនៅខាងក្រៅផងដែរ។ [១២]

កុមាររស់នៅក្នុងពន្ធនាគារជាមួយឪពុកម្តាយពុំមែនជាទណ្ឌិតទេ ហេតុនេះពួកគេមិនត្រូវទទួលទណ្ឌកម្មណាមួយឡើយ។ លីកាដូមានគោលបំណងធានាឱ្យកុមារគ្រប់គ្នាដែលរស់នៅក្នុងពន្ធនាគារមានអាហារ ទឹក កន្លែងរស់នៅល្អ ការព្យាបាល ការរៀនសូត្រ ឱកាសលេងកំសាន្ត និង ការមានទំនាក់ទំនាក់ជាមួយសង្គមខាងក្រៅឱ្យបានសមរម្យ។

□□□

---

[១១] Op Cit 5, Jen Makin

[១២] ឯកសារដដែលដូចខាងលើ ។

# ៥. អនុសាសន៍ និង សេចក្តីសន្និដ្ឋាន

លីកាដូសូមអំពាវនាវដល់សហគមន៍អន្តរជាតិ និង សង្គមស៊ីវិលនៅកម្ពុជាជួយបញ្ចុះបញ្ចូលរាជរដ្ឋាភិបាលកម្ពុជាឱ្យកែលំអស្ថានភាពរស់នៅរបស់ម្តាយ និង កុមារដែលរស់នៅក្នុងពន្ធនាគារ ។

ជាពិសេស លីកាដូ សូមផ្តល់ជូននូវអនុសាសន៍ដូចខាងក្រោម :

***ចំពោះទណ្ឌិត***

- ទណ្ឌិតនារីត្រូវដាក់ឱ្យដាច់ដោយឡែកពីទណ្ឌិតបុរស ដោយមានកន្លែងធំទូលាយគ្រប់គ្រាន់សម្រាប់ទណ្ឌិតម្នាក់ៗ ។
- ត្រូវផ្តល់អាហារដែលមានជីវជាតិគ្រប់គ្រាន់ដល់ទណ្ឌិតទាំងអស់បីពេលក្នុងមួយថ្ងៃ មានទឹកពិសាជាប្រចាំ ព្រមទាំងមានសម្លៀកបំពាក់ និង សម្ភារៈអនាម័យគ្រប់គ្រាន់ផងដែរ ។
- ត្រូវផ្តល់ការថែទាំសុខភាពដល់ទណ្ឌិតទាំងអស់ជាប្រចាំ ។
- អង្គការដៃគូដែលមានជំនាញខាងអប់រំមនុស្សចាស់ គួរធ្វើកិច្ចសន្យាជួយបង្រៀនជំនាញនានាដល់ទណ្ឌិតនារី និង បុរសទាំងអស់ ។ កិច្ចការនេះត្រូវរៀបចំឱ្យសមស្របតាមបរិបទពន្ធនាគារ ។ ការបង្រៀនបែបនេះគួរតែរៀបចំមួយវគ្គម្តងៗ ជាកម្មសិក្សាខ្លីៗ ឬ ប្រសើរជាងនេះគួរតែរៀបចំជាកម្មវិធីចម្រុះមួយ ។ ប្រធានបទអាចរួមបញ្ចូលដូចជា:
  - កម្មវិធីអក្ខរកម្ម
  - ការដោះស្រាយទំនាស់ដោយអហិង្សានៅក្នុងបរិបទពន្ធនាគារ
  - សិទ្ធិកុមារ
  - ការថែទាំសុខភាពកុមារ និងទារក
  - ការវិវឌ្ឍន៍ដំណាក់ដំបូងរបស់កុមារ
  - និងជំនាញវិជ្ជាជីវៈនានា
- អំពើហិង្សារវាងទណ្ឌិតត្រូវតែត្រួតពិនិត្យដោយមន្ត្រីពន្ធនាគារ ហើយមានវិធានការដាក់ទណ្ឌកម្មតាមបែបអហិង្សា ដូចជាការដកសិទ្ធិក្នុងការចេញក្រៅហាត់ប្រាណជាដើម ។
- មន្ត្រីពន្ធនាគារដែលប្រព្រឹត្តអំពើហិង្សាលើទណ្ឌិតក្នុងពន្ធនាគារ ត្រូវតែទទួលទោស ហើយត្រូវបាត់បង់តួនាទី ។

- ត្រូវអនុញ្ញាតឱ្យទណ្ឌិតទាំងអស់ចេញក្រៅបន្ទប់ឃុំឃាំងហាត់ប្រាណ ជាប្រចាំរៀងរាល់ថ្ងៃជាអប្បបរមា ៤ ម៉ោងក្នុង១ថ្ងៃ ហើយមិនត្រូវបង្ខំទណ្ឌិតឱ្យបង់ប្រាក់កាស ដើម្បីទទួលបានសិទ្ធិនេះឡើយ ។
- មិនត្រូវបង្ខំទណ្ឌិតធ្វើការឱ្យមន្ត្រីពន្ធនាគារ ក្នុងស្ថានភាពដែលមិនល្អឡើយ ហើយទណ្ឌិតដែលធ្វើការងារជាប្រចាំត្រូវតែបានទទួលប្រាក់កម្រៃសមរម្យ ។
- គួរអនុញ្ញាតទណ្ឌិតឱ្យជួបគ្រួសារ និង មិត្តភក្តិ ហើយមិនត្រូវបង្ខំអ្នកដែលមកសួរសុខទុក្ខបង់ប្រាក់កាស ដើម្បីមានសិទ្ធិចូលសាកសួរសុខទុក្ខឡើយ ។

## ***ចំពោះកុមារ និង នារីមានផ្ទៃពោះរស់នៅក្នុងពន្ធនាគារ***

- គួរផ្តល់ម្ហូបអាហារបន្ថែម ទឹក សម្លៀកបំពាក់ សម្ភារៈអនាម័យ កន្លែងរស់នៅសមរម្យ និង ការព្យាបាលជម្ងឺជាប្រចាំដល់កុមារ និង នារីមានផ្ទៃពោះ ។
- គួរផ្តល់ម្ហូបអាហារបន្ថែមដល់នារីមានផ្ទៃពោះទាំងសម្រាប់មុន និងក្រោយពេលមានផ្ទៃពោះ ដើម្បីធានាឱ្យទារកមានសុខភាពល្អ និង ម្តាយមានទឹកដោះគ្រប់គ្រាន់សម្រាប់បំបៅកូន ។
- គួរអនុញ្ញាតឱ្យនារីមានផ្ទៃពោះបានទទួលការថែទាំសុខភាពជាប្រចាំ ។
- គួរបញ្ជូននារីមានផ្ទៃពោះទៅសម្រាលកូននៅមន្ទីរពេទ្យ ។
- គួរអនុញ្ញាតឱ្យកុមារទៅលេងគ្រួសារនៅខាងក្រៅពន្ធនាគារជាប្រចាំ ។
- គួរការពារកុមារកុំឱ្យឃើញ និង ទទួលអំពើហិង្សាដែលប្រព្រឹត្តដោយមន្ត្រីពន្ធនាគារទៅលើទណ្ឌិតដទៃ ។
- ត្រូវស៊ើបអង្កេតករណីមន្ត្រីពន្ធនាគារ ឬ ទណ្ឌិតណាដែលប្រព្រឹត្តហិង្សាលើកុមារ និង ដាក់ទណ្ឌកម្មសមស្រប ។
- គួរផ្តល់មូលនិធិដល់ ជំហ៊ានទី២នៃគម្រោងផ្តល់ជំនួយម្ហូបអាហារដល់កុមារ និង នារីមានផ្ទៃពោះ និងអនុវត្តឱ្យបានកាន់តែឆាប់ នៅក្នុងគ្រប់ពន្ធនាគារទាំងអស់ដែលមានម្តាយ និងកុមាររស់នៅ ។

## ***ជំហ៊ានទី២ នៃគម្រោងគួរសម្រេចឱ្យបាន :***

- កន្លែងរស់នៅប្រកបដោយសុវត្ថិភាពសម្រាប់កុមារ ម្តាយរបស់កុមារ និង នារីមានផ្ទៃពោះ ។
- គួរអនុញ្ញាតឱ្យកុមារមានសេរីភាពខ្លះ នៅក្នុងពន្ធនាគារ ហើយមិនត្រូវចាក់សោឱ្យនៅក្នុងបន្ទប់ ២៤ ម៉ោងក្នុង ១ ថ្ងៃទេ ។

- គួរបង្កើតក្រុមលេងសាកល្បងមួយក្នុងពន្ធនាគារដោយមានកុមារលើសពី ៥ នាក់[១៣] អង្គការមិនមែនរដ្ឋាភិបាល ដែលមានជំនាញខាងការលូតលាស់រីកចម្រើនរបស់កុមារតូចៗ អាចត្រូវការ ដើម្បីឱ្យជួយក្នុងការអនុវត្តវិធានការនេះ ។ ក្រុមលេងអាចជួយកុមារឱ្យលេង និង រៀនសូត្រជាមួយគ្នា ហើយបន្ថែមជំនាញ និង ចំណេះដឹងរបស់ម្តាយក្នុងការលូតលាស់របស់កុមារ ។ អ្នកសម្របសម្រួលគួរនាំយកមកជាមួយនូវរូបភាព សម្ភារៈប្រើប្រាស់នានា ដើម្បីឱ្យកុមារបានរៀនសូត្រអំពីសង្គមខាងក្រៅ[១៤] ។
- ចំពោះពន្ធនាគារណាដែលមានកុមារតិចតួច អាចសុំអង្គការដៃគូឱ្យរៀបចំសម្រាប់កុមារធំ (អាយុពី ៣-៦ ឆ្នាំ) ឱ្យមានឱកាសទៅរៀនសាលាមត្តេយ្យនៅក្នុងមូលដ្ឋាន។

## សេចក្តីសន្និដ្ឋាន

មានម្តាយ និង កុមារជាច្រើន ដែលកំពុងប្រឈមមុខការលំបាកដូចដែលនាងលីណា និង កុមារីម៉ាលីបានជួបប្រទះ ខណៈរស់នៅក្នុងពន្ធនាគារ ។ ចំពោះនារីដែលត្រូវផ្តន្ទាទោសយូរឆ្នាំ ពួកគេប្រហែលជាអាចរស់នៅជាមួយកូនរបស់គេរយៈពេលពីរបីឆ្នាំប៉ុណ្ណោះ ។ វាជាការសំខាន់បំផុតដែលទណ្ឌិតនារីទាំងអស់ (តាមពិតទណ្ឌិតទាំងអស់) បានរស់នៅក្នុងស្ថានភាពល្អប្រសើរ ប៉ុន្តែចំពោះទណ្ឌិតនារីទាំងឡាយដែលយកកូនមករស់នៅជាមួយក្នុងពន្ធនាគារ នោះបញ្ហាសំខាន់បំផុត គឺត្រូវគាំទ្រគ្រួសារទាំងនេះ ដូច្នេះទំនាក់ទំនងរវាងម្តាយ និង កូនត្រូវបានរក្សា និងគោរព ។ សំខាន់ជាងនេះទៅទៀត គឺត្រូវការពារសិទ្ធិរបស់កុមារដែលរស់នៅ និង លូតលាស់ដឹងក្តីក្នុងពន្ធនាគារ ។

ម៉ាលីជាកុមារីតូចម្នាក់ដែលត្រូវបានបង្ខំឱ្យចូលរួមចំណែកក្នុងកិច្ចបម្រើទោសជាមួយម្តាយ ។ ដើម្បីជួយឱ្យកុមារមានការលូតលាស់ដឹងក្តីឱ្យបានកាន់តែប្រសើរជាងមុនក្នុងពន្ធនាគារ ត្រូវចាត់វិធានការឱ្យបានហ្មត់ចត់ ដើម្បីធានាឱ្យកុមារដូចជាម៉ាលី ត្រូវបានផ្តល់ឱកាសសម្រាប់អនាគត ។ ជីវិតក្នុងពន្ធនាគារអាចមានភាពខុសពីនេះច្រើនសម្រាប់ម៉ាលី ប្រសិនបើនាងត្រូវបានផ្តល់នូវអាហារ ការព្យាបាលជម្ងឺ ការសិក្សាអប់រំ មានទំនាក់ទំនងជាមួយពិភពខាងក្រៅជាប្រក្រតី ។ល។ ការរស់នៅក្នុងនៅក្នុងពន្ធនាគារ គឺជាទណ្ឌកម្មគ្រប់គ្រាន់ហើយសម្រាប់ម្តាយដែលធ្លាប់ត្រូវបានផ្តន្ទាទោស ។ នេះជាអំពើអយុត្តិធម៌ណាស់ដែលដាក់ទណ្ឌកម្មចំពោះកូនៗរបស់ម្តាយដែលជា ទណ្ឌិតដោយព្រោះតែគ្មានជម្រើស ហើយតម្រូវឱ្យរស់នៅក្នុងពន្ធនាគារដូច្នេះ។

□□□

[១៣] ឧទាហរណ៍ -នៅមណ្ឌលអប់រំកែប្រែទី២ (ម.២) បច្ចុប្បន្ន មានកុមារ ៦ នាក់ ហើយពន្ធនាគារតាខ្មៅមានកុមារ ៨នាក់ ។

[១៤] OP cit 5, Jen Makin

http://www.licadho.org/